# សិក្ខាបទវិភង្គបាលីប្រែ

# ២២៧ សិក្ខាបទ

ការផ្សាយរបស់វត្តព្រះគន្ធកុដិ

រៀបរៀងដោយ

**ភិក្ខុមេត្តាធរោ មឿន សឺន**

(សម្រាប់ជាធម្មទាន)

ពុទ្ធសករាជ ២៥៦៧

# សិក្ខាបទវិភង្គបាលីប្រែ

## ២២៧ សិក្ខាបទ

ការផ្សាយរបស់វត្តព្រះគន្ធកុដិ

រៀបរៀងដោយ

ភិក្ខុមេត្តាធនោ មឿន សីន

(សម្រាប់ជាធម្មទាន)

ពុទ្ធសករាជ ២៥៦៧

# ថេរគាថា ព្រះឧបាលិត្ថេរ

សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ
មិត្តេ ភជេយ្យ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។

កុលបុត្ត ចេញ(ចាកឃរាវាស) ដោយសទ្ធា ហើយបួសថ្មី ជានវភិក្ខុ គប្បីគប់រកកល្យាណមិត្រទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិត ដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។

សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ
សង្ឃស្មឹ វិហរំ ភិក្ខុ សិក្ខេថ វិនយំ ពុធោ ។

កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធា ហើយបួសថ្មី ជានវភិក្ខុ អ្នកមានប្រាជ្ញា ការនៅក្នុងពួក គប្បីសិក្សានូវវិន័យ ។

សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ
កប្បាកប្បេសុ កុសលោ ចរេយ្យ អបុរក្ខតោ ។

កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធា ហើយបួសថ្មី ជានវភិក្ខុ ជាអ្នកឈ្លាស ក្នុងហេតុដែលគួរនឹងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឱ្យ (ពួកកិលេសមានតណ្ហាជាដើម) ប្រព្រឹត្តទៅក្នុងខាងមុខបាន ។

(សុត្តន្តបិដក ៥៦/ ទំព័រ ២០១)

# អារម្ភកថា

ក្នុងសៀវភៅ សិក្ខាបទវិភង្គបាលីប្រែ ២២៧ សិក្ខាបទនេះ ខ្ញុំបានរួបរួមឈ្មោះសិក្ខាបទ និងសេចក្តីប្រែឈ្មោះសិក្ខាបទតាម បិដកខ្មែរ និងអដ្ឋកថាសមន្តបាសាទិកាខ្មែរ ដោយគ្រប់សិក្ខាបទ ទាំងអស់សម្រាប់សមណសិស្សបានសិក្សា នឹងអាចយល់សេចក្តីក្នុង សិក្ខាបទនីមួយៗបានខ្លះ ដែលមាននៅក្នុងក្នុងសៀវភៅតូចនេះដោយ សង្ខេបសេចក្តីក្នុងឈ្មោះសិក្ខាបទ ។

ខ្ញុំយល់ឃើញថា សៀវភៅនេះមានប្រយោជន៍ដ៏ឧត្តម ដល់សមណសិស្សដែលពុំចាំសិក្ខាបទទាំងបាលី និងប្រែ បុកចាំដែរ តែពុំបានចាំដោយសព្វគ្រប់ ។ ខ្ញុំបានសរសេរឈ្មោះសិក្ខាបទមក ដើម្បីឱ្យសមណសិស្ស ងាយស្រួលក្នុងការសិក្សា យល់ដឹងសេចក្តីក្នុងសិក្ខាបទនេះផងដែរ ។

សៀវភៅ សិក្ខាបទវិភង្គបាលីប្រែ នេះខ្ញុំបានសរសេរជាភាសាបាលី មួងរួចនៅហើយ ដោយមានព្រះថេរអនុគ្រោះ ជួយពិនិត្យផ្ទៀងផ្ទាត់កែ សម្រួលអក្ខរាវិរុទ្ធ ច្រើនព្រះអង្គ បានឃើញថាត្រឹមត្រូវល្អហើយ ។

ខ្ញុំសូមប្រគេនជូនភាគផលកុសល ដែលកើតអំពីការរៀបរៀង សៀវភៅនេះ ប្រគេនជូន ចំពោះបុព្វការីបុគ្គលទាំងឡាយរបស់ខ្ញុំ មានមាតា បិតានិងព្រះឧបជ្ឈាយាចារ្យជាដើម, សូមលោកជួបប្រទះតែនឹងសេចក្តី សុខចម្រើនសមតាមប្រាថ្នា ។

សូមព្រះពុទ្ធសាសនា ដែលមានព្រះវិន័យជាឫសគល់បានចម្រើនរុងរឿង ថ្កាន ដោយមានភិក្ខុបរិស័ទប្រតិបត្តិម្ចាត់ចត់បានឋិតថេរចីរកាលក្នុងកម្ពុជ រដ្ឋជាអង្វែងតទៅ ។

វត្តព្រះកន្ធកុដិ ក្រុងបាត់ដំបង ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

(១៤-០៩-២០២៣)

**មឿន-សឺន *(ភិក្ខុមេត្តាធនោ )***

# មាតិកាធម៌ ទំព័រ

ថេរគាថា ព្រះឧទាលិត្ថេរៈ....................ក
អារម្ភកថា....................១
[១] មេថុនធម្មសិក្ខាបទទី១....................១
[២] អទិន្នាទានសិក្ខាបទទី២....................១
[៣] មនុស្សវិគ្គហសិក្ខាបទទី៣....................២
[៤] ឧត្តរិមនុស្សធម្មសិក្ខាបទទី៤....................៣
[៥] សុក្កវិស្សដ្ឋិ សិក្ខាបទទី១....................៤
[៦] កាយសំសគ្គ សិក្ខាបទទី២....................៤
[៧] ទុដ្ឋុល្លវាចា សិក្ខាបទទី៣....................៤
[៨] អត្តកាមបារិចរិយា សិក្ខាបទទី៤....................៥
[៩] សញ្ចរិត្ត សិក្ខាបទទី៥....................៥
[១០] កុដិការ សិក្ខាបទទី៦....................៦
[១១] វិហារការ សិក្ខាបទទី៧....................៧
[១២] បឋមទុដ្ឋទោស សិក្ខាបទទី៨....................៧
[១៣] ទុតិយទុដ្ឋទោស សិក្ខាបទទី៩....................៨
[១៤] បឋមសង្ឃភេទ សិក្ខាបទទី១០....................៩
[១៥] ទុតិយសង្ឃភេទ សិក្ខាបទទី១១....................១០
[១៦] ទុព្វច សិក្ខាបទទី១២....................១១
[១៧] កុលទូសក សិក្ខាបទទី១៣....................១៣

[១៨] បឋមអនិយត សិក្ខាបទទី ១........................................................១៦
[១៩] ទុតិយអនិយត សិក្ខាបទទី ២........................................................១៧
[២០] បឋមកឋិន សិក្ខាបទទី ១........................................................១៨
[២១] ឧទ្ទោសិត សិក្ខាបទទី២........................................................១៨
[២២] តតិយកឋិន សិក្ខាបទទី៣........................................................១៩
[២៣] បុរាណចីវរធោវាបន សិក្ខាបទទី ៤........................................................១៩
[២៤] ចីវរប្បដិគ្គហណ សិក្ខាបទទី៥........................................................២០
[២៥]អញ្ញាតកវិញ្ញត្តិ សិក្ខាបទទី ៦........................................................២០
[២៦] តតុត្តរិ សិក្ខាបទទី ៧........................................................២១
[២៧] បឋមឧបក្ខដ សិក្ខាបទទី ៨........................................................២១
[២៨] ទុតិយឧបក្ខដ សិក្ខាបទទី ៩........................................................២២
[២៩] រាជ សិក្ខាបទទី ១០........................................................២៣
[៣០] កោសិយ សិក្ខាបទទី ១........................................................២៦
[៣១] សុទ្ធកាឡក សិក្ខាបទទី ២........................................................២៦
[៣២] ទ្វេភាគ សិក្ខាបទទី ៣........................................................២៦
[៣៣] ឆព្វស្ស សិក្ខាបទទី ៤........................................................២៧
[៣៤] និសីទនសន្ថត សិក្ខាបទទី ៥........................................................២៧
[៣៥] ឯឡកលោម សិក្ខាបទទី ៦........................................................២៨
[៣៦] ឯឡកលោមធោវាបន សិក្ខាបទទី ៧........................................................២៨
[៣៧] រូបិយ សិក្ខាបទទី ៨........................................................២៩

[៣៨] រូបិយសំវោហារ សិក្ខាបទទី ៩ .......... ២៩

[៣៩] កយវិក្កយ សិក្ខាបទទី ១០ .......... ៣០

[៤០] បត្ត សិក្ខាបទទី ១ .......... ៣១

[៤១] ឩនបញ្ចពន្ធន សិក្ខាបទទី ២ .......... ៣១

[៤២] ភេសជ្ជ សិក្ខាបទទី ៣ .......... ៣២

[៤៣] វស្សិកសាដិកចីវរ សិក្ខាបទទី ៤ .......... ៣២

[៤៤] អច្ឆិន្ន សិក្ខាបទទី ៥ .......... ៣៣

[៤៥] សុត្តវិញ្ញត្តិ សិក្ខាបទទី ៦ .......... ៣៣

[៤៦] មហាបេសការ សិក្ខាបទទី ៧ .......... ៣៣

[៤៧] អច្ចេកចីវរ សិក្ខាបទទី ៨ .......... ៣៤

[៤៨] សាសង្ក សិក្ខាបទទី ៩ .......... ៣៥

[៤៩] បរិណាត សិក្ខាបទទី ១០ .......... ៣៦

[៥០] មុសាវាទ សិក្ខាបទទី ១ .......... ៣៧

[៥១] ឱមសវាទ សិក្ខាបទទី ២ .......... ៣៧

[៥២] បេសុញ្ញវាទ សិក្ខាបទទី ៣ .......... ៣៧

[៥៣] បទសោធម្ម សិក្ខាបទទី ៤ .......... ៣៧

[៥៤] សហសេយ្យ សិក្ខាបទទី ៥ .......... ៣៨

[៥៥] ទុតិយសហសេយ្យ សិក្ខាបទទី ៦ .......... ៣៨

[៥៦] ធម្មទេសនា សិក្ខាបទទី ៧ .......... ៣៨

[៥៧] ភូតារោចន សិក្ខាបទ ទី ៨ .......... ៣៩

[៥៨] ទុដ្ឋុល្លាវាចន សិក្ខាបទ ទី ៩.....................................................................៣៩
[៥៩] បឋវីខណន សិក្ខាបទ ទី ១០.......................................................................៣៩
[៦០] ភូតគាម សិក្ខាបទទី ១១............................................................................៤០
[៦១] អញ្ញវាទ សិក្ខាបទទី ១២..........................................................................៤០
[៦២] ឧជ្ឈាបន សិក្ខាបទទី ១៣.........................................................................៤០
[៦៣] បឋមសេនាសន សិក្ខាបទទី ១៤...............................................................៤១
[៦៤] ទុតិយសេនាសនសិក្ខាបទទី ១៥...............................................................៤១
[៦៥] អនុប្បខជ្ជ សិក្ខាបទទី ១៦.........................................................................៤២
[៦៦] និកឌ្ឍន សិក្ខាបទទី ១៧............................................................................៤២
[៦៧] វេហាសកុដិ សិក្ខាបទទី ១៨......................................................................៤២
[៦៨] មហល្លកវិហារ សិក្ខាបទទី ១៩.................................................................៤៣
[៦៩] សប្បាណក សិក្ខាបទទី ២០.......................................................................៤៣
[៧០] ឱវាទ សិក្ខាបទទី ២១..................................................................................៤៤
[៧១] អត្ថង្គត សិក្ខាបទទី២២.............................................................................៤៤
[៧២] ភិក្ខុនីឧបស្សយ សិក្ខាបទទី២៣.................................................................៤៤
[៧៣] អាមិស សិក្ខាបទទី ២៤..............................................................................៤៥
[៧៤] ចីវរទានសិក្ខាបទទី ២៥.............................................................................៤៥
[៧៥] ចីវរសិព្វន សិក្ខាបទទី ២៦.........................................................................៤៥
[៧៦] សំវិធាន សិក្ខាបទទី ២៧.............................................................................៤៦
[៧៧] នាវាភិរូហន សិក្ខាបទទី ២៨.......................................................................៤៦

[៧៨] បរិចាចន សិក្ខាបទទី ២៩.....................................................................៤៧
[៧៩] រហោនិសជ្ជ សិក្ខាបទទី៣០...................................................................៤៧
[៨០] អាវសថបិណ្ឌ សិក្ខាបទទី ៣១...............................................................៤៨
[៨១] គណភោជនសិក្ខាបទទី ៣២...................................................................៤៨
[៨២] បរម្បរភោជនសិក្ខាបទទី ៣៣.................................................................៤៩
[៨៣] កាណមាតា សិក្ខាបទទី ៣៤...................................................................៤៩
[៨៤] បឋមបវារណា សិក្ខាបទទី ៣៥...............................................................៥០
[៨៥] ទុតិយបវារណា សិក្ខាបទទី ៣៦.............................................................៥០
[៨៦] វិកាលភោជន សិក្ខាបទទី ៣៧.................................................................៥១
[៨៧] សន្និធិការកសិក្ខាបទទី ៣៨.....................................................................៥១
[៨៨] បណីតភោជន សិក្ខាបទទី ៣៩.................................................................៥១
[៨៩] ទន្តពោណ សិក្ខាបទទី៤០.......................................................................៥២
[៩០]អចេលកសិក្ខាបទទី ៤១...........................................................................៥៣
[៩១] ឧយ្យោជនសិក្ខាបទទី ៤២.......................................................................៥៣
[៩២]សភោជនសិក្ខាបទទី ៤៣...........................................................................៥៤
[៩៣] រហោបដិច្ឆន្ន សិក្ខាបទទី៤៤...................................................................៥៤
[៩៤]រហោនិសជ្ជ សិក្ខាបទទី ៤៥....................................................................៥៤
[៩៥] ចារិត សិក្ខាបទទី ៤៦...............................................................................៥៥
[៩៦] មហានាម សិក្ខាបទទី ៤៧.........................................................................៥៥
[៩៧] ឧយ្យុត្ត សិក្ខាបទទី ៤៨.............................................................................៥៦

[៩៨] សេនាវាសសិក្ខាបទទី ៤៩........................................................................៥៦

[៩៩] ឧយ្យោធិក សិក្ខាបទទី ៥០........................................................................៥៦

[១០០] សុរាបាន សិក្ខាបទទី ៥១........................................................................៥៧

[១០១] អង្គុលិបតោទក សិក្ខាបទទី ៥២........................................................................៥៧

[១០២] ហស្សធម្ម សិក្ខាបទទី ៥៣........................................................................៥៧

[១០៣] អនាទរិយ សិក្ខាបទទី ៥៤........................................................................៥៧

[១០៤] ភឹសាបន សិក្ខាបទទី ៥៥........................................................................៥៨

[១០៥] ជោតិសមាទហន សិក្ខាបទទី ៥៦........................................................................៥៨

[១០៦] ន្ហាន សិក្ខាបទទី ៥៧........................................................................៥៨

[១០៧]ទុព្វណ្ណករណ សិក្ខាបទទី ៥៨........................................................................៥៩

[១០៨] វិកប្បនសិក្ខាបទទី ៥៩........................................................................៥៩

[១០៩] ចីវរាបនិធាន សិក្ខាបទទី ៦០........................................................................៦០

[១១០] សញ្ចិច្ចបាណ សិក្ខាបទទី ៦១........................................................................៦១

[១១១] សប្បាណក សិក្ខាបទទី ៦២........................................................................៦១

[១១២] ឧក្កោដន សិក្ខាបទទី ៦៣........................................................................៦១

[១១៣] ទុដ្ឋុល្ល សិក្ខាបទទី ៦៤........................................................................៦២

[១១៤] ឩនវីសតិ សិក្ខាបទទី ៦៥........................................................................៦២

[១១៥] ថេយ្យសត្ថ សិក្ខាបទទី ៦៦........................................................................៦២

[១១៦] សំវិធាន សិក្ខាបទទី ៦៧........................................................................៦៣

[១១៧] អរិដ្ឋ សិក្ខាបទទី ៦៨........................................................................៦៣

[១១៩] ឧត្តិត្តសម្ភោគ សិក្ខាបទទី ៦៩ ...... ៦៤
[១១៩] កណ្ដក សិក្ខាបទទី ៧០ ...... ៦៥
[១២០] សហធម្មិក សិក្ខាបទទី ៧១ ...... ៦៧
[១២១] វិលេខន សិក្ខាបទទី ៧២ ...... ៦៧
[១២២] មោហាន សិក្ខាបទទី ៧៣ ...... ៦៨
[១២៣] បហារ សិក្ខាបទទី ៧៤ ...... ៦៩
[១២៤] តលសត្តិក សិក្ខាបទទី ៧៥ ...... ៦៩
[១២៥] អមូលក សិក្ខាបទទី ៧៦ ...... ៦៩
[១២៦] សញ្ចិច្ច សិក្ខាបទទី ៧៧ ...... ៧០
[១២៧] ឧបស្សុតិក សិក្ខាបទទី ៧៨ ...... ៧០
[១២៨] កម្មបដិពាហន សិក្ខាបទទី ៧៩ ...... ៧១
[១២៩] ឆន្ទំអទត្វាគមន សិក្ខាបទទី ៨០ ...... ៧១
[១៣០] ឧទត្វ សិក្ខាបទទី ៨១ ...... ៧១
[១៣១] បរិណាមន សិក្ខាបទទី ៨២ ...... ៧២
[១៣២] អន្តេបុរ សិក្ខាបទទី ៨៣ ...... ៧៣
[១៣៣] រតន សិក្ខាបទទី ៨៤ ...... ៧៣
[១៣៤] វិកាលគាមប្បវេសន សិក្ខាបទទី ៨៥ ...... ៧៤
[១៣៥] សូចិឃរ សិក្ខាបទទី ៨៦ ...... ៧៤
[១៣៦] មញ្ចបីឋ សិក្ខាបទទី ៨៧ ...... ៧៤
[១៣៧] តូលោនទ្ធ សិក្ខាបទទី ៨៨ ...... ៧៥

[១៣៨] និសីទន សិក្ខាបទទី ៨៩.....................................................................៧៥

[១៣៩] កណ្ឌុប្បដិច្ឆាទិ សិក្ខាបទទី ៩០............................................................៧៦

[១៤០] វស្សិកសាដិក សិក្ខាបទទី ៩១...............................................................៧៦

[១៤១] សុគតចីវរ សិក្ខាបទទី ៩២....................................................................៧៧

[១៤២] អញ្ញាតិកាយ សិក្ខាបទទី ១....................................................................៧៨

[១៤៣] ឧប្បដិភាសេយ្យ សិក្ខាបទទី ២...............................................................៧៨

[១៤៤] សេក្ខសម្មតិ សិក្ខាបទទី ៣....................................................................៧៩

[១៤៥] អរញ្ញកសេនាសន សិក្ខាបទទី ៤..............................................................៨០

[១៤៦] បឋមបរិមណ្ឌល សិក្ខាបទទី ១.................................................................៨១

[១៤៧] ទុតិយបរិមណ្ឌល សិក្ខាបទទី ២...............................................................៨១

[១៤៨] បឋមសុប្បដិច្ឆន្ន សិក្ខាបទទី ៣.................................................................៨១

[១៤៩] ទុតិយសុប្បដិច្ឆន្ន សិក្ខាបទទី ៤...............................................................៨១

[១៥០] បឋមសុសំវុតំ សិក្ខាបទទី ៥...................................................................៨២

[១៥១] ទុតិយសុសំវុតំ សិក្ខាបទទី ៦..................................................................៨២

[១៥២] បឋមឱក្ខិត្តចក្ខុ សិក្ខាបទទី ៧.................................................................៨២

[១៥៣] ទុតិយឱក្ខិត្តចក្ខុ សិក្ខាបទទី ៨...............................................................៨២

[១៥៤] បឋមឧក្ខិត្តក សិក្ខាបទទី ៩...................................................................៨៣

[១៥៥] ទុតិយឧក្ខិត្តក សិក្ខាបទទី ១០................................................................៨៣

[១៥៦] បឋមឧជ្ជគ្ឃិក សិក្ខាបទទី ១១...............................................................៨៣

[១៥៧] ទុតិយឧជ្ជគ្ឃិក សិក្ខាបទទី ១២.............................................................៨៣

[១៥៨] បឋមអប្បសទ្ទ សិក្ខាបទទី ១៣.....................................................៨៤
[១៥៩] ទុតិយអប្បសទ្ទ សិក្ខាបទទី ១៤.....................................................៨៤
[១៦០] បឋមកាយប្បចាលក សិក្ខាបទទី ១៥.....................................................៨៤
[១៦១] ទុតិយកាយប្បចាលក សិក្ខាបទទី ១៦.....................................................៨៤
[១៦២] បឋមពាហុប្បចាលក សិក្ខាបទទី ១៧.....................................................៨៥
[១៦៣] ទុតិយពាហុប្បចាលក សិក្ខាបទទី ១៨.....................................................៨៥
[១៦៤] បឋមសីសប្បចាលក សិក្ខាបទទី ១៩.....................................................៨៥
[១៦៥] ទុតិយសីសប្បចាលក សិក្ខាបទទី ២០.....................................................៨៥
[១៦៦] បឋមខម្ភកត សិក្ខាបទទី ២១.....................................................៨៦
[១៦៧] ទុតិយខម្ភកត សិក្ខាបទទី ២២.....................................................៨៦
[១៦៨] បឋមឱគុណ្ឋិត សិក្ខាបទទី ២៣.....................................................៨៦
[១៦៩] ទុតិយឱគុណ្ឋិត សិក្ខាបទទី ២៤.....................................................៨៦
[១៧០] ឧក្កុដិក សិក្ខាបទទី ២៥.....................................................៨៧
[១៧១] បល្លត្ថិក សិក្ខាបទទី ២៦.....................................................៨៧
[១៧២] សក្កច្ចបដិគ្គហណ សិក្ខាបទទី ២៧.....................................................៨៧
[១៧៣] បត្តសញ្ញីបដិគ្គហណ សិក្ខាបទទី ២៨.....................................................៨៨
[១៧៤] សមសូបកបដិគ្គហណ សិក្ខាបទទី ២៩.....................................................៨៧
[១៧៥] សមតិត្តិកបដិគ្គហណ សិក្ខាបទទី ៣០.....................................................៨៨
[១៧៦] សក្កច្ចបិណ្ឌបាតភុញ្ជន សិក្ខាបទទី ៣១.....................................................៨៩
[១៧៧] បត្តសញ្ញីបិណ្ឌបាតភុញ្ជន សិក្ខាបទទី ៣២.....................................................៨៨

[១៧៨] សបទានបិណ្ឌបាតភុញ្ជន សិក្ខាបទទី ៣៣......................៨៩
[១៧៩] សមសូបកបិណ្ឌបាតភុញ្ជន សិក្ខាបទទី ៣៤....................៨៩
[១៨០] នថូបិកតោមទ្ទិនភុញ្ជន សិក្ខាបទទី ៣៥................................៩០
[១៨១] នសូបព្យញ្ជនោទនបដិច្ឆាទន សិក្ខាបទទី ៣៦......................៩០
[១៨២] នសូបោទនវិញ្ញត្តិ សិក្ខាបទទី ៣៧..........................................៩០
[១៨៣] នឧជ្ឈានសញ្ញីបត្តាលោកន សិក្ខាបទទី ៣៨......................៩១
[១៨៤] នាតិមហន្តកពឡករណ សិក្ខាបទទី ៣៩............................៩១
[១៨៥] បរិមណ្ឌលអាលោបករណ សិក្ខាបទទី ៤០..........................៩១
[១៨៦] នអនាហដទ្វារវិវរណ សិក្ខាបទទី ៤១...................................៩២
[១៨៧] នសព្វហត្ថបក្ខិបន សិក្ខាបទទី ៤២........................................៩២
[១៨៨] នសកពឡព្យាហរណ សិក្ខាបទទី ៤៣.................................៩២
[១៨៩] នបិណ្ឌុក្ខេបកភុញ្ជន សិក្ខាបទទី ៤៤...................................៩៣
[១៩០] នកពឡាវច្ឆេទក សិក្ខាបទទី ៤៥.............................................៩៣
[១៩១] នអវគណ្ឌការកភុញ្ជន សិក្ខាបទទី ៤៦...............................៩៣
[១៩២] នហត្ថនិទ្ធូនកភុញ្ជន សិក្ខាបទទី ៤៧....................................៩៣
[១៩៣] នសិត្ថាវការកភុញ្ជន សិក្ខាបទទី ៤៨...................................៩៤
[១៩៤ នជិវ្ហានិច្ឆារកភុញ្ជន សិក្ខាបទទី ៤៩........................................៩៤
[១៩៥] នចបុចបុការកភុញ្ជន សិក្ខាបទទី ៥០...................................៩៤
[១៩៦] នសុរុសុរុការកភុញ្ជន សិក្ខាបទទី ៥១....................................៩៤
[១៩៧] នហត្ថនិល្លេហកភុញ្ជន សិក្ខាបទទី ៥២................................៩៥

[១៩៨] នបត្តនិល្លេហកភុញ្ជន សិក្ខាបទទី ៥៣.................................៩៥
[១៩៩] នឱដ្ឋនិល្លេហកភុញ្ជន សិក្ខាបទទី ៥៤.....................................៩៥
[២០០] នសាមិសបដិគ្គហណា សិក្ខាបទទី ៥៥......................................៩៥
[២០១] នសសិដ្ឋកឆឌ្ឌន សិក្ខាបទទី ៥៦..................................................៩៦
[២០២] នឆត្តបាណិទេសន សិក្ខាបទទី ៥៧..........................................៩៦
[២០៣] នទណ្ឌបាណិទេសន សិក្ខាបទទី ៥៨.......................................៩៦
[២០៤] នសត្ថបាណិទេសន សិក្ខាបទទី ៥៩.........................................៩៧
[២០៥] នអាវុធបាណិទេសន សិក្ខាបទទី ៦០.......................................៩៧
[២០៦] នបាទុការុឡ្ហទេសន សិក្ខាបទី ៦១...........................................៩៨
[២០៧] នឧបាហនទេសន សិក្ខាបទទី  ៦២............................................៩៨
[២០៨] នយានគតទេសន សិក្ខាបទទី ៦៣..............................................៩៨
[២០៩] នសយគតទេសន សិក្ខាបទី ៦៤..................................................៩៩
[២១០] នបល្លត្ថិកទេសន សិក្ខាបទទី ៦៥.............................................៩៩
[២១១] នវេដ្ឋិតសីសទេសន សិក្ខាបទទី ៦៦.........................................៩៩
[២១២] នឱគុណ្ឋិតសីសទេសន សិក្ខាបទទី ៦៧..............................១០០
[២១៣] នឆមាយទេសេន សិក្ខាបទទី ៦៨..........................................១០០
[២១៤] ននីចាសនទេសន សិក្ខាបទទី ៦៩.........................................១០០
[២១៥] នឋិតទេសន សិក្ខាបទទី ៧០...................................................១០១
[២១៦] នបច្ឆតោទេសេន សិក្ខាបទទី ៧១.........................................១០១
[២១៧] នឧប្បថទេសេន សិក្ខាបទទី ៧២............................................១០១

[២១៨] នឋិតករណោ សិក្ខាបទទី ៧៣..................................................១០២

[២១៩] នហារិតកណោ សិក្ខាបទទី ៧៤..................................................១០២

[២២០] នឧទកករណោ សិក្ខាបទទី ៧៥..................................................១០២

[២២១] សម្មុខាវិនយោ ទាតព្វោ ទី១..................................................១០៣

[២២២] សតិវិនយោ ទាតព្វោ ទី២..................................................១០៣

[២២៣] អមូឡ្ហវិនយោ ទាតព្វោ ទី៣..................................................១០៣

[២២៤] បដិញ្ញាយ ការេតព្វំ ទី៤..................................................១០៣

[២២៥] យេភុយ្យសិកា ទី៥..................................................១០៣

[២២៦] តស្ស ចាបិយសិកា ទី៦ ..................................................១០៣

[២២៧] តិណវត្ថារកោតិ ទី៧..................................................១០៣

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# បារាជិកកណ្ឌ

## [១] មេថុនធម្មសិក្ខាបទទី១

សិក្ខាបទ ការសេពមេថុនធម្ម

(បិដក.១.៧២)

**យោ បន ភិក្ខុ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវេយ្យ អន្តមសោ តិរច្ឆានគតាយបិ បារាជិកោ ហោតិ អសំវាសោ ។**

ភិក្ខុណាមួយដល់ព្រមដោយសិក្ខានឹងសាជីវៈ (ដែលតថាគតបញ្ញត្តហើយ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឱ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅសូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសង្វាសគ្មាន ។

## [២] អទិន្នាទានសិក្ខាបទទី២

សិក្ខាបទ ការលួចទ្រព្យដែលគេមិនបានឱ្យ

(បិដក .១ .១៥០)

**យោ បន ភិក្ខុ គាមា វា អរញ្ញា វា អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យ យថារូបេ អទិន្នាទានេ រាជានោ ចោរំ គហេត្វា ហនេយ្យុំ វា ពន្ធេយ្យុំ វា បព្វាជេយ្យុំ វា ចោរោសិ ពាលោសិ មូឡ្ហោសិ ថេនោសីតិ តថារូបំ ភិក្ខុ អទិន្នំ អាទិយមានោ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។**

ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឱ្យ ដោយចំណែកនៃចិត្តលួច អំពីស្រុកក្តី ព្រៃក្តី ស្តេចទាំងឡាយចាប់បានចោរហើយត្រូវសម្លាប់ក្តី ឃុំខាំងក្តី

និរទោសក្តី ដោយពាក្យថា ឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្សលួច ព្រោះអទិន្នាទានមានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យ ដែលគេមិនបានឱ្យ មានសភាពយ៉ាងនោះ ភិក្ខុនេះក្តី ក៏ត្រូវអាបត្តិបារាជិករកសង្វាសគ្មាន (គឺឥតមានកិរិយានៅរួបរួមគ្នាបាន ) ។

## [៣] មនុស្សវិគ្គហសិក្ខាបទទី៣

សិក្ខាបទ ការសម្លាប់មនុស្ស

(បិដក.១.២៣៨)

**យោ បន ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេយ្យ សត្ថហារកំ វាស្ស បរិយេសេយ្យ មរណវណ្ណំ វា សំវណ្ណេយ្យ មរណាយ វា សមាទបេយ្យ អម្ភោ បុរិស កឹ តុយ្ហិមិនា បាបកេន ទុជ្ជីវិតេន មតន្តេ ជីវិតា សេយ្យោតិ ឥតិ ចិត្តមនោ ចិត្តសង្កប្បោ អនេកបរិយាយេន មរណវណ្ណំ វា សំវណ្ណេយ្យ មរណាយ វា សមាទបេយ្យ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។**

ភិក្ខុណាមួយក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឱ្យឃ្លាតចាកជីវិតក្តី ទោះបីស្វែងរកគ្រឿងសាស្ត្រាវុធ (ឱ្យគេសម្លាប់) រាងកាយមនុស្សនោះក្តី ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ថា នែបុរសដ៏ចំរើន អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ (ភិក្ខុ) មានចិត្តគិតដូច្នេះ មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ គប្បីពណ៌នាគុណនៃសេចក្តីស្លាប់ ឬគប្បីណែនាំដើម្បីសេចក្តីស្លាប់ដោយអនេកបរិយាយ ភិក្ខុនេះក្តី ហៅថាត្រូវអាបត្តិបារាជិកមិនមានសំវាសឡើយ ។

## [៤] ឧត្តរិមនុស្សធម្មសិក្ខាបទទី៤

សិក្ខាបទ ការពោលអួតឧត្តរិមនុស្សធម្ម

(បិដក.១.២៩៩)

**យោ បន ភិក្ខុ អនភិជានំ ឧត្តរិមនុស្សធម្មំ អត្តុបនាយិកំ អលមរិយញ្ញាណទស្សនំ សមុទាចរេយ្យ ឥតិ ជានាមិ ឥតិ បស្សាមីតិ តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា អាបន្នោ វិសុទ្ធាបេក្ខោ ឯវំ វទេយ្យ អជានមេវំ អាវុសោ អវចំ ជានាមិ អបស្សំ បស្សាមិ តុច្ឆំ មុសា វិលបិន្តិ អញ្ញត្រ អធិមានា អយម្បិ បារាជិកោ ហោតិ អសំវាសោ ។**

ភិក្ខុណាមួយ មិនដឹងច្បាស់ហើយពោលអួតឧត្តរិមនុស្សធម្ម ជាធម៌មានញាណ (សេចក្ដីដឹង) នឹងទស្សនៈ (កិរិយាឃើញ) ដ៏ប្រសើរ អាចកំចាត់នូវកិលេស គួរបង្អោនមកដាក់ក្នុងខ្លួនដោយពាក្យថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ លុះដល់សម័យដទៃអំពីនោះមក ទោះមានគេសាកសួរក្ដី ឥតមានគេសាកសួរក្ដី ក៏ហៅថាត្រូវអាបត្តិបារាជិកហើយ (ទោះបី) មានប្រាថ្នាចង់ឱ្យបរិសុទ្ធ ហើយត្រឡប់ជានិយាយកែសំនួនយ៉ាងនេះវិញថា នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ (ប៉ុន្តែ) ពោលថាដឹង ខ្ញុំមិនឃើញយ៉ាងនេះទេ (ប៉ុន្តែ) ពោលថាឃើញ ខ្ញុំពោលកុហកសោះទេ ភិក្ខុនេះក្តីក៏ត្រូវអាបត្តិបារាជិក រកសំវាសគ្មានវៀរលែងតែសំគាល់ថាខ្លួនបានត្រាស់ដឹង ។

## ចប់បារាជិកកណ្ឌ

# សង្ឃាទិសេសកណ្ឌ

## [៥] សុក្កវិស្សដ្ឋិ សិក្ខាបទទី១

សិក្ខាបទ ការបញ្ចេញទឹកសុក្កៈ
(បិដក.២.៧)

**សញ្ចេតនិកា សុក្កវិស្សដ្ឋិ អញ្ញត្រ សុបិនន្តា សង្ឃាទិសេសោ ។**

ភិក្ខុក្លែងញ៉ាំងទឹកសុក្កឱ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស លើកលែងតែយល់សប្តិ ។

## [៦] កាយសំសគ្គ សិក្ខាបទទី២

សិក្ខាបទ ការស្ទាបអង្អែលកាយមាតុគ្រាម
(បិដក.២.៥៦)

**យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជេយ្យ ហត្ថគ្គាហំ វា វេណិគ្គាហំ វា អញ្ញតរស្ស វា អញ្ញតរស្ស វា អង្គស្ស បរាមសនំ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយគឺកាមរាគគ្របសង្កត់ហើយ មានចិត្តប្រែប្រួលហើយ ដល់ព្រមនូវកាយសំសគ្គ មួយអន្លើដោយមាតុគ្រាម ទោះចាប់ដៃក្តី ចាប់ផ្នួងសក់ក្តី ឬស្ទាបអង្អែលអវយវៈត្រង់ណា ៗ ក្តី ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

## [៧] ទុដ្ឋុល្លវាចា សិក្ខាបទទី៣

សិក្ខាបទ ការពោលពាក្យអាក្រក់
(បិដក.២.៨៨)

**យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសេយ្យ យថាតំ យុវា យុវតឹ មេថុនុបសញ្ហិតាហិ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយ គឺរាគគ្របសង្កត់ហើយមានចិត្តប្រែប្រួល និយាយចង់

មាតុគ្រាមដោយសម្ដីអាក្រក់ ដូចប្រុសកម្លោះនិយាយចង់ស្រីក្រមុំ ដោយសម្ដីដែលប្រកបដោយមេថុន ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

## [៨] អត្តកាមបារិចរិយា សិក្ខាបទទី៤

សិក្ខាបទ ការឱ្យមាតុគ្រាបម្រើខ្លួនដោយកាម

(បិ៨ក.២.១០៩)

**យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន មាតុគ្គាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសេយ្យ ឯតទគ្គំ ភគិនិ បារិចរិយានំ យា មាទិសំ សីលវន្តំ កល្យាណធម្មំ ព្រហ្មចារី ឯតេន ធម្មេន បរិចរេយ្យាតិ មេថុនូបសញ្ហិតេន សង្ឃាទិសេសោ ។**

ភិក្ខុណាមួយ គឺរាគគ្របសង្កត់ហើយមានចិត្តប្រែប្រួល ពោលសរសើរការបម្រើជាកាមដើម្បីខ្លួនក្នុងសំណាក់នៃមាតុគ្រាម ដោយសំដីប្រកបដោយមេថុនធម្មថាស្រីណា គប្បីបម្រើនូវភិក្ខុមានសីល មានធម៌ជាកុសល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរប្រហែលដូចអាត្មាដោយធម៌នេះ ម្នាលប្អូនស្រី ការបម្រើនេះរបស់ស្រីនោះជាការប្រសើរជាងការបម្រើទាំងអស់ (ពោលពាក្យដូច្នោះ) ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

## [៩] សញ្ចរិត្ត សិក្ខាបទទី៥

សិក្ខាបទ ការដឹកនាំបុរសស្ត្រីឱ្យបានគ្នាជាប្ដីប្រពន្ធ

(បិ៨ក.២.១៣២)

**យោ បន ភិក្ខុ សញ្ចរិត្តំ សមាបជ្ជេយ្យ ឥត្ថិយា វា បុរិសមតឹ បុរិសស្ស វា ឥត្ថីមតឹ ជាយត្តនេ វា ជារត្តនេ វា អន្តមសោ តំខណិកាយបិ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយប្រព្រឹត្តនិយាយដឹកនាំ គឺប្រាប់សេចក្ដីប្រាថ្នាប្រុសដល់ស្រីក្ដី ប្រាប់

សេចក្តីប្រាថ្នាស្រីដល់ប្រុសក្តី ឱ្យបានគ្នាជាប្រពន្ធក្តីជាប្តីឬជាសហាយក្តី ដោយហោចទៅសូម្បីតែស្រីដែលបុរសគប្បីនៅរួមអស់ទ្ធម្មមួយរំពេច នោះត្រូវអាបត្តិសង្ឃាទិសេស ។

## [១០] **កុដិការ សិក្ខាបទទី៦**

សិក្ខាបទ ការធ្វើកុដិ

(បិដក.២.១៩៣)

**សញ្ញាចិកាយ បន ភិក្ខុនា កុដឹ ការយមានេន អស្សាមិកំ អត្តុទ្ទេសំ បមាណិកា ការេតព្វា តត្រិទំ បមាណំ ទីឃសោ ទ្វាទស វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ សត្តន្តរា ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ ។ សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ សញ្ញាចិកាយ កុដឹ ការេយ្យ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ បមាណំ វា អតិក្កាមេយ្យ សង្ឃាទិសេសោ ។**

កាលភិក្ខុឱ្យគេធ្វើកុដិដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួនដោយការសូមគ្រឿងឧបករណ៍មកខ្លួនឯង គប្បីធ្វើឱ្យប្រកបដោយប្រមាណ ប្រមាណកុដិនោះគឺ បណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាមដោយចំអាមព្រះសុគតវាស់ខាងក្នុង ត្រូវនាំពួកភិក្ខុមកដើម្បីសម្តែងទីឱ្យ ភិក្ខុទាំងនោះគប្បីសម្តែងទីដែលមិនមានអន្តរាយ នឹងមានឧបចារ បើភិក្ខុឱ្យគេធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ក្នុងទីដែលមានអន្តរាយ នឹងមិនមានឧបចារក្តី មិនបាននាំពួកភិក្ខុមកដើម្បីសម្តែងទីឱ្យក្តី ធ្វើឱ្យកន្លងហួសប្រមាណក្តី ត្រូវអាបត្តិសង្ឃាទិសេស ។

## [១១] វិហារការ សិក្ខាបទទី៧

សិក្ខាបទ ការធ្វើលំនៅ (កុដិធំ)

(បិដក.២.២២៩)

**មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន សស្សាមិកំ អត្តុទ្ទេសំ ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ ។ សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ មហល្លកំ វិហារំ ការេយ្យ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ សង្ឃាទិសេសោ ។**

ភិក្ខុកាលឱ្យគេធ្វើវិហារមានម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ត្រូវនាំភិក្ខុទាំងឡាយមកសម្តែងទីឱ្យ ភិក្ខុទាំងឡាយនោះត្រូវសម្តែងទីដែលមិនមានសេចក្តីរង្កៀស មានឧបចារ ថាបើទីដីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារហើយ ភិក្ខុគប្បីឱ្យធ្វើវិហារធំ ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសម្តែងទីឱ្យ ត្រូវអាបត្តិសង្ឃាទិសេស ។

## [១២] បឋមទុដ្ឋទោស សិក្ខាបទទី៨

សិក្ខាបទ ការចោទអាបត្តិ រកដើមហេតុគ្មាន

(បិដក.២.២៥៨)

**យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ ទោសោ អប្បតីតោ អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេយ្យ អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា អមូលកញ្ចេវ តំ អធិករណំ ហោតិ ភិក្ខុ ច ទោសំ បតិដ្ឋាតិ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយ មានសេចក្តីក្រោធប្រទូស្ត មានចិត្តអាក់អន់ ចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូលដោយបំណងថា អញត្រូវធ្វើដូចម្តេចឱ្យភិក្ខុ

នោះឃ្លាតចាកព្រហ្មចរិយធម៌នេះបាន លុះសម័យខាងក្រោយតពីនោះមក ទោះគេសាកសួរក្តី គេមិនសាកសួរក្តី អធិករណ៍នោះប្រាកដជាគ្មានមូល ភិក្ខុអ្នកចោទនោះក៏ប្តេជ្ញាទោស (ដោយខ្លួនឯង) ត្រូវអាបត្តិសង្ឃាទិសេស ។

## [១៣] ទុតិយទុដ្ឋទោស សិក្ខាបទទី៩

សិក្ខាបទ ការចោទ អាងលេសណាទីមួយ

(បិដក.២.២៧៨)

**យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ ទោសោ អប្បតីតោ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេយ្យ អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា អញ្ញភាគិយញ្ចេវ តំ អធិករណំ ហោតិ កោចិ ទេសោ លេសមត្តោ ឧបាទិន្នោ ភិក្ខុ ច ទោសំ បតិដ្ឋាតិ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយមានទោសទ្រុស្តហើយ មានសេចក្តីក្រោធ មានចិត្តមិនរីករាយ បានកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុដោយអាបត្តិបារាជិក ដោយបំណងថា ធ្វើម្តេចហ្ន៎ អញគប្បីញុំាងភិក្ខុនោះឱ្យឃ្លាតចាកព្រហ្មចរិយធម៌ ( សាសនា ) នេះបាន លុះសម័យខាងក្រោយតពីនោះមក ភិក្ខុអ្នកចោទនោះមានគេសាកសួរក្តីមិនមានគេសាកសួរក្តី តែអធិករណ៍នោះជាចំណែកដទៃទេ ភិក្ខុកាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ហើយភិក្ខុប្តេជ្ញាទោស ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។

## [១៤] បឋមសង្ឃភេទ សិក្ខាបទទី១០

សិក្ខាបទ ការបំបែកសង្ឃ

(បិដក.២.២៩៨)

**យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ ។ សមេតាយស្មា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោ ។**

ភិក្ខុណាមួយព្យាយាមដើម្បីទំលាយសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឱ្យសង្ឃបែកគ្នាហើយតាំងនៅ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ភិក្ខុនោះដោយពាក្យយ៉ាងនេះថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឱ្យសង្ឃបែកគ្នាហើយតាំងនៅ សូមលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះថា ព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នាមិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ភិក្ខុនោះកាលភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះហើយ នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ពោលប្រដៅហាមប្រាម) ជាកំណត់បីដង ដើម្បីឱ្យលះបង់សង្ឃភេទកម្មនោះ កាលបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគម្រប់បីដងហើយ ភិក្ខុ

នោះបានលះបង់សង្ឃភេទនោះចេញ ការលះបង់បាននេះជាការប្រពៃ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

## [១៥] ទុតិយសង្ឃភេទ សិក្ខាបទទី១១

សិក្ខាបទ ការប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ

(បិដក.២.៣០៥)

**តស្សេវ ខោ បន ភិក្ខុស្ស ភិក្ខូ ហោន្តិ អនុវត្តកា វគ្គវាទកា ឯកោ វា ទ្វេ វា តយោ វា, តេ ឯវំ វទេយ្យុំ មា អាយស្មន្តោ ឯតំ ភិក្ខុំ កិញ្ចិ អវចុត្ថ, ធម្មវាទី ចេសោ ភិក្ខុ, វិនយវាទី ចេសោ ភិក្ខុ, អម្ហាកញ្ចេសោ ភិក្ខុ ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ ជានាតិ នោ ភាសតិ អម្ហាកម្បេតំ ខមតីតិ ។ តេ ភិក្ខូ ភិក្ខូហិ ឯវមស្សុ វចនីយា មា អាយស្មន្តោ ឯវំ អវចុត្ថ ន ចេសោ ភិក្ខុ ធម្មវាទី ន ចេសោ ភិក្ខុ វិនយវាទី, មា អាយស្មន្តានម្បិ សង្ឃភេទោ រុច្ចិត្ថ, សមេតាយស្មន្តានំ សង្ឃេន, សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច តេ ភិក្ខូ ភិក្ខូហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យុំ តេ ភិក្ខូ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ, យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យុំ ឥច្ចេតំ កុសលំ, នោ ចេ បដិនិស្សជ្ជេយ្យុំ សង្ឃាទិសេសោ ។**

ភិក្ខុទាំងឡាយមួយរូបក្តី ពីររូបក្តី បីរូបក្តី ជាអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះឯង នឹងជាអ្នកពោលប្រកាន់ពួក ហើយពួកភិក្ខុទាំងនោះពោលហាម ភិក្ខុទាំងឡាយ (ដែលជាភិក្ខុបរិសុទ្ធ) យ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ព្រោះភិក្ខុនេះជាអ្នកពោលត្រូវតាមធមិផង ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផង ម្យ៉ាងទៀត ភិក្ខុនេះកាន់យកសេចក្តីពេញចិត្តនឹងសេចក្តីគាប់ចិត្តរបស់ពួក

យើង ទើបពោល លោកដឹងសេចក្តីពេញចិត្តជាដើមរបស់ពួកយើង ទើបពោល អំពើនេះក៏គាប់ចិត្តដល់យើងទាំងឡាយ ។ ពួកភិក្ខុទាំងនោះត្រូវតែភិក្ខុទាំងឡាយ (ដែលបរិសុទ្ធ) ពោលយ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ព្រោះភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវធម៌ផង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំងឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើង សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅសប្បាយ ។ ពួកភិក្ខុទាំងនោះ កាលដែលភិក្ខុទាំងឡាយពោលហាមយ៉ាងនេះ ក៏នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ពួកភិក្ខុទាំងនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈគម្រប់បីដង ដើម្បីឱ្យលះបង់នូវកម្មនោះ ។ កាលបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មដល់គម្រប់បីដងហើយ ពួកភិក្ខុទាំងនោះលះបង់នូវរឿងនោះចេញ ការលះបង់បានយ៉ាងនេះជាការល្អណាស់បើ មិនលះបង់ទេត្រូវអាបត្តិសង្ឃាទិសេស ។

## [១៦] **ទុព្វច សិក្ខាបទទី១២**

សិក្ខាបទ ការប្រដៅក្រ

(បិដក.២.៣១៨)

**ភិក្ខុ បនេវ ទុព្វចជាតិកោ ហោតិ ឧទ្ទេសបរិយាបន្នេសុ សិក្ខាបទេសុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោតិ " មា មំ អាយស្មន្តោ កិញ្ចិ អវចុត្ថ កល្យាណំ វា បាបកំ វា អហម្បាយស្មន្តេ ន កិញ្ចិ វក្ខាមិ កល្យាណំ វា បាបកំ វា, វិរមថាយស្មន្តោ មម វចនាយាតិ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ "មា**

អាយស្មា អត្តានំ អវចនីយំ អកាសិ, វចនីយមេវ អាយស្មា អត្តានំ ករោតុ អាយស្មាបិ ភិក្ខូ វទេតុ សហធម្មេន, ភិក្ខូបិ អាយស្មន្តំ វក្ខន្តិ សហធម្មេន, ឯវំ សំវឌ្ឍា ហិ តស្ស ភគវតោ បរិសា យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋា-បនេនា″តិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ, យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោ ។

ភិក្ខុមានជាតិដែលគេប្រដៅក្រ កាលភិក្ខុទាំងឡាយពោលប្រដៅ (ខ្លួន) ដោយធម៌ក្នុងសិក្ខាបទទាំងឡាយដែលរាប់ចូលក្នុងឧទ្ទេស (បាតិមោក្ខ) ធ្វើខ្លួនឱ្យគេប្រដៅមិនបាន ដោយពាក្យថា លោកម្ចាស់ទាំងឡាយ លោកកុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ចំណែកខ្ញុំក៏នឹងមិនពោលពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងលោកម្ចាស់ទាំងឡាយដែរ បពិត្រលោកម្ចាស់ទាំងឡាយ ចូរលោកលែងនិយាយប្រដៅខ្ញុំទៅ ។ ភិក្ខុនោះត្រូវភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះថា លោកម្ចាស់កុំធ្វើខ្លួនឱ្យគេប្រដៅមិនបានឡើយ លោកម្ចាស់ត្រូវតែធ្វើខ្លួនឱ្យគេប្រដៅបានផង ចំណែកលោកម្ចាស់ចូរប្រដៅភិក្ខុទាំងឡាយដោយសហធម៌ (ពុទ្ធប្បញ្ញត្តិ) សូម្បីពួកភិក្ខុក៏ពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិស័ទរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះ តែងចម្រើនឡើងដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា នឹងដោយញ៉ាំងគ្នានឹងគ្នាឱ្យចេញចាកអាបត្តិយ៉ាងនេះ ។ កាលភិក្ខុទាំងឡាយពោលប្រដៅភិក្ខុនោះយ៉ាងនេះ (ភិក្ខុនោះ) ក៏នៅប្រកាន់យ៉ាងហ្នឹងដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ហាម) ជាគម្រប់បីដង ដើម្បីឱ្យលះបង់នៅកម្មនោះ បើភិក្ខុនោះ កាលពួកភិក្ខុសូត្រសមនុភាសនកម្ម

ជាគម្រប់បីដង ហើយលះបង់រឿងនោះបាន ការលះបង់បានយ៉ាងនេះ ជាការរួចទោស បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

## [១៧] កុលទូសក សិក្ខាបទទី១៣

សិក្ខាបទ ការប្រទុស្តត្រកូល

(បិដក.២.៣៤១)

ភិក្ខុ បនេវ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ កុលទូសកោ បាបសមាចារោ, តស្ស ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច, កុលានិ ច តេន ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ "អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច, កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច, បក្កមតាយស្មា ឥមម្ហា អាវាសា, អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តេ ភិក្ខូ ឯវំ វទេយ្យ "ឆន្ទគាមិនោ ច ភិក្ខូ, ទោសគាមិនោ ច ភិក្ខូ, មោហគាមិនោ ច ភិក្ខូ, ភយគាមិនោ ច ភិក្ខូ តាទិសិកាយ អាបត្តិយា ឯកច្ចំ បព្វាជេន្តិ ឯកច្ចំ ន បព្វាជេន្តីតិ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ "មា អាយស្មា ឯវំ អវច, ន ច ភិក្ខូ ឆន្ទគាមិនោ, ន ច ភិក្ខូ ទោសគាមិនោ, ន ច ភិក្ខូ មោហគាមិនោ, ន ច ភិក្ខូ ភយគាមិនោ, អាយស្មា ខោ កុលទូសកោ បាបសមាចារោ, អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច, បក្កមតាយស្មា ឥមម្ហា អាវាសា, អលន្តេ ឥធ វាសេនា"តិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ, យាវតតិយញ្ចេ

**សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ បដិនិស្សជ្ជេយ្យ, សង្ឃាទិសេសោ ។**

ភិក្ខុចូលទៅជិតអាស្រ័យស្រុក ឬនិគម កន្លែងណាមួយហើយនៅ ជាអ្នកទ្រុស្ត ត្រកូលមានសេចក្តីប្រព្រឹត្តិអាក្រក់ ។ សេចក្តីប្រព្រឹត្តិអាក្រក់នោះឯង ប្រាកដជា គេឃើញផង គេឮផង ត្រកូលទាំងឡាយ ដែលភិក្ខុនោះទ្រុស្តហើយ ប្រាកដ ជាគេឃើញផង គេឮផង ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយស្តីឱ្យយ៉ាង នេះថា លោកដ៏មានអាយុជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តិអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាស នេះទៅ លោកមិនគួរនៅទីនេះទេ ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយ ប្រដៅយ៉ាងនេះ ត្រឡប់ថាឱ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា ភិក្ខុ ទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខឹងផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង (ព្រោះ) ភិក្ខុទាំងឡាយនោះ បណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ដោយអាបត្តិដូចគ្នាទេ ។ ភិក្ខុនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះ ថា លោកដ៏មានអាយុចូរកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តី ស្រឡាញ់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីស្អប់ ភិក្ខុទាំងឡាយមិនលុះក្នុង សេចក្តីល្ងង់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីខ្លាច លោកដ៏មានអាយុឯង ជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់ លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឬផង ត្រកូលទាំងឡាយសោត

ដែលលោកដ៏មានអាយុទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញចាកអាវាសនេះទៅ លោកកុំនៅក្នុងអាវាសនេះ ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ នៅតែប្រកាន់លទ្ធិយ៉ាងនោះដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាម ដើម្បីឱ្យលះបង់អំពើអាក្រក់នោះកំណត់បីដង ។ ភិក្ខុនោះបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មកំណត់បីដង លះអំពើអាក្រក់នោះបានសេចក្តីលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចប់សង្ឃាទិសេសកណ្ឌ**

# អនិយតកណ្ឌ

## [១៨] បឋមអនិយត សិក្ខាបទទី ១

### សិក្ខាបទ ការអង្គុយឬដេកជាមួយមាតុគ្រាមក្នុងទីកំបាំងភ្នែក

(បិដក.២.៣៥៣)

**យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេយ្យ, តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា, និសជ្ជំ ភិក្ខុ បដិជានមានោ តិណ្ណំ ធម្មានំ អញ្ញតរេន ការេតព្វោ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ, តេន សោ ភិក្ខុ ការេតព្វោ, អយំ ធម្មោ អនិយតោ ។**

ភិក្ខុណាមួយ តែម្នាក់នឹងម្នាក់ អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច)បាន ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះ ហើយគប្បីចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះមែន) វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកានោះមានវាចាគួរជឿបាន ចោទដោយអាបត្តិណា វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ អាបត្តិនេះ ឈ្មោះថាអនិយតៈ (មិនទៀង) ។

# [១៩] ទុតិយអនិយត សិក្ខាបទទី ២

សិក្ខាបទ ការអង្គុយឬដេកជាមួយមាតុគ្រាមក្នុងទីមិនកំបាំងភ្នែក
(បិដក.២.៣៦២)

**ន ហេវ ខោ បន បដិច្ឆន្នំ អាសនំ ហោតិ នាលំកម្មនិយំ, អលញ្ច ខោ ហោតិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិតុំ ។ យោ បន ភិក្ខុ តថារូបេ អាសនេ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា ទ្វិន្នំ ធម្មានំ អញ្ញតរេន វទេយ្យ សង្ឃាទិសេសេន វា បាចិត្តិយេន វា និសជ្ជំ ភិក្ខុ បដិជានមានោ ទ្វិន្នំ ធម្មានំ អញ្ញតរេន ការេតព្វោ សង្ឃាទិសេសេន វា បាចិត្តិយេន វា, យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ, តេន សោ ភិក្ខុ ការេតព្វោ, អយម្បិ ធម្មោ អនិយតោ ។**

អាសនៈដែលគេមិនបានបិទបាំងមែន មិនល្មមធ្វើ (សេវនកិច្ច) បានមែន តែថាគួរអាចនឹងនិយាយ ចែចង់មាតុគ្រាមដោយវាចាអាក្រក់បាន ។ ភិក្ខុណាមួយ តែម្នាក់នឹងម្នាក់អង្គុយក្នុងទីកំបាំងលើអាសនៈមានសភាពយ៉ាងនោះ ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះហើយ ចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះ) វិន័យធរត្រូវវិនិច្ឆ័យ ដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេស ឬបាចិត្តិយ ម៉្យាងទៀត ឧបាសិកាដែលមានសំដីគួរជឿបាននោះចោទដោយអាបត្តិណា វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ សូម្បីធមិនេះក៏ឈ្មោះអនិយតដែរ ។

**ចប់អនិយតកណ្ឌ**

# និស្សគ្គិយកណ្ឌ

## ចីវរវគ្គទី១

### [២០] បឋមកឋិន សិក្ខាបទទី ១

សិក្ខាបទ ការអស់អំណាចកឋិន ទុកអតិរេកចីវរហួស ១០ ថ្ងៃ

(បិដក.៣.៤)

**និដ្ឋិតចីវរស្មឹំ ភិក្ខុនា ឧព្ភតស្មឹំ កឋិនេ ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ, តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ ។**

កាលបើចីវរសម្រេចហើយ (ក្តី) កឋិនដោះហើយ (ក្តី) ភិក្ខុត្រូវទុក អតិរេកចីវរបានត្រឹមតែ ១០ ថ្ងៃ បើឱ្យកន្លងហួសពី ១០ ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

### [២១] ឧទោសិត សិក្ខាបទទី២

សិក្ខាបទ ការនៅប្រាសចាកចីវរ កន្លងមួយរាត្រី

(បិដក.៣.១៤)

**និដ្ឋិតចីវរស្មឹំ ភិក្ខុនា ឧព្ភតស្មឹំ កឋិនេ ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យ, អញ្ញត្រ ភិក្ខុសម្មតិយា, និស្សគ្គិយំ បាចិត្តិយំ ។**

កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ត្រូវនិស្សគ្គិយបាចិត្តិយវៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។

## [២២] តតិយកឋិន សិក្ខាបទទី៣

សិក្ខាបទ ការទុកអកាលចីវរហួសមួយខែ

(បិដក.៣.២៦)

**និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ភិក្ខុនោ បនេវ អកាលចីវរំ ឧប្បជ្ជេយ្យ, អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វំ,បដិគ្គហេត្វា ខិប្បមេវ ការេតព្វំ នោ ចស្ស បារិបូរិ មាសបរមន្តេន ភិក្ខុនា តំ ចីវរំ និក្ខិបិតព្វំ ឩនស្ស បារិបូរិយា សតិយា បច្ចាសាយ ។ តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយ, និស្សគ្គិយំ បាចិត្តិយំ ។**

កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើអកាលចីវរកើតឡើងចំពោះភិក្ខុ ទាំងភិក្ខុសោតក៏ត្រូវការ (អកាលចីវរនោះ) ត្រូវទទួលចុះលុះទទួលរួចហើយត្រូវរវៀសរវៃធ្វើឱ្យឆាប់ បើចីវរនោះខ្វះធ្វើមិនគ្រាន់ទេ ភិក្ខុនោះមានបំណងថា នឹងរកចីវរមកបំពេញនូវចីវរដែលខ្វះ (នោះ) ត្រូវទុកចីវរនោះបាន យ៉ាងយូរបំផុតត្រឹម ១ ខែ បើទុកឱ្យលើសពី ១ ខែ នោះទៅ បើទុកជាមានបំណងថា នឹងរកចីវរមកបំពេញទៀតក៏ដោយ គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។

## [២៣] បុរាណចីវរធោវាបន សិក្ខាបទទី ៤

សិក្ខាបទ ការប្រើភិក្ខុនីមិនមែនញាតិឱ្យលាងចីវរចាស់

(បិដក.៣.៣៤)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេយ្យ វា រជាបេយ្យ វា អាកោដាបេយ្យ វា, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយប្រើនាងភិក្ខុនីដែលមិនមែនញាតិ ឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យគក់ឬបោកក្តី នូវចីវរចាស់ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

## [២៤] ចីវរប្បដិគ្គហណ សិក្ខាបទទី៥

សិក្ខាបទ ការទទួលចីវរពីដៃភិក្ខុនីមិនមែនជាញាតិ

(បិដក.៣.៤៥)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហេយ្យ អញ្ញត្រ បារិវដ្ដកា, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយទទួលយកចីវរអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា ។

## [២៥]អញ្ញាតកវិញ្ញត្តិ សិក្ខាបទទី ៦

សិក្ខាបទ ការសូមចីវរពីគ្រហស្ថមិនមែនជាញាតិ

(បិដក.៣.៥៤)

**យោ បន ភិក្ខុ អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេយ្យ អញ្ញត្រ សមយា និស្សគ្គិយំ បាចិត្តិយំ ។ តត្ថាយំ សមយោ, អច្ឆិន្នចីវរោ វា ហោតិ ភិក្ខុ, នដ្ឋចីវរោ វា, អយំ តត្ថ សមយោ ។**

ភិក្ខុណាមួយសុំចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុមានចីវរដែលចោរដណ្ដើមយកទៅ ឬភិក្ខុមានចីវរខូចនេះជាសម័យក្នុងសិក្ខាបទនោះ ។

## [២៦] តតុត្តរិ សិក្ខាបទទី ៧

សិក្ខាបទ ការសូមចីវរហួសពីអន្តរវាសកៈ និង ឧត្តរាសង្គៈ

(បិដក.៣.៨៩)

**តញ្ចេ អញ្ញាតកោ គហបតិ វា គហបតានី វា ពហូហិ ចីវរេហិ អភិហដ្ឋុំ បវារេយ្យ, សន្តរុត្តរបរមន្តេន ភិក្ខុនា តតោ ចីវរំ សាទិតព្វំ ។ តតោ វេ ឧត្តរឹ សាទិយេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

បើគហបតីក្តី គហបតានីក្តី បវារណាភិក្ខុនោះ ដើម្បីឱ្យកាន់យកតាមតម្រូវការដោយចីវរដ៏ច្រើន ភិក្ខុនោះគប្បីត្រេកអរចំពោះចីវរនោះ តែត្រឹមអន្តរវាសកៈ និងឧត្តរាសង្គៈ បើភិក្ខុត្រេកអរឱ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយ-បាចិត្តិយ ។

## [២៧] បឋមឧបក្ខដ សិក្ខាបទទី ៨

សិក្ខាបទ ការទៅនិយាយនឹងគ្រហស្ថមិនមែនញាតិឱ្យគេប្រគេនចីវរល្អ

(បិដក.៣.៦៤)

**ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកស្ស គហបតិស្ស វា គហបតានិយា វា ចីវរចេតាបនំ ឧបក្ខដំ ហោតិ "ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេស្សាមី"តិ ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ" សាធុ វត មំ អាយស្មា ឥមិនា ចីវរចេតាបនេន ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេហី"តិ កល្យាណកម្យតំ ឧបាទាយ, និស្សគ្គិយំ បាចិត្តិយំ ។**

តម្លៃចីវរដែលគហបតីក្តី គហបតានីក្តី មិនមែនជាញាតិចំពោះភិក្ខុហើយតាំងទុកថា ខ្ញុំនឹងទិញចីវរដោយតម្លៃចីវរនេះ ហើយនឹងឱ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរ ។ បើភិក្ខុនោះ ដែលគេមិនបានបវារណាមុន ហើយចូលទៅក្នុងទី

នោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ល្អហើយអ្នកដ៏មានអាយុ អ្នកចូរទិញចីវរមានបែបយ៉ាងនេះក្តី ៧ ដោយតម្លៃចីវរនេះ ហើយឱ្យអាត្មាស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

## [២៨] ទុតិយឧបក្ខដ សិក្ខាបទទី ៩

សិក្ខាបទ ការឱ្យគេរួបរួមថ្លៃគ្នា ដើម្បីទិញចីវរឱ្យល្អ

(បិដក.៣.៧០)

**ភិក្ខុំ បនេវ ឧទ្ទិស្ស ឧភិន្នំ អញ្ញាតកានំ គហបតីនំ វា គហបតានីនំ វា បច្ចេកចីវរចេតាបនា ឧបក្ខដា ហោន្តិ ឥមេហិ មយំ បច្ចេកចីវរចេតាបនេហិ បច្ចេកចីវរានិ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេហិ អច្ឆាទេស្សាមា"តិ, ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ "សាធុ វត មំ អាយស្មន្តោ ឥមេហិ បច្ចេកចីវរចេតាបនេហិ ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេថ ឧភោ វ សន្តា ឯកេនា"តិ កល្យាណកម្យតំ ឧបាទាយ និស្សគ្គិយំ បាចិត្តិយំ ។**

តម្លៃចីវរផ្សេងគ្នា ដែលគហបតីក្តី គហបតានីក្តី មិនមែនជាញាតិទាំងពីរនាក់ ចំពោះភិក្ខុ ១ រូប ហើយតម្កល់ទុកថា យើងទាំងឡាយនឹងទិញចីវរទាំងឡាយ មួយម្នាក់ ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះ ហើយនឹងឱ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរទាំងឡាយ ។

បើភិក្ខុនោះ គេមិនបានបវារណា ជាមុនហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ស្រួលហើយអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងពីរចូររួបរួមជាមួយគ្នា ទិញចីវរបែបយ៉ាងនេះផង ៧ ដោយតម្លៃចីវរម្ចាស់ផ្សេងគ្នាទាំងនេះ ហើយឱ្យអាត្មាស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

## [២៩] រាជ សិក្ខាបទទី ១០

សិក្ខាបទ ការតឹងទារចីវរហួសបីដង នឹងឈរហួស ប្រាំមួយដង
(បិដក.៣.៧៩)

ភិក្ខុំ បនេវ ឧទ្ទិស្ស រាជា វា រាជភោគ្គោ វា ព្រាហ្មណោ វា គហបតិកោ វា ទូតេន ចីវរចេតាបនំ បហិណេយ្យ "ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេហី"តិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ "ឥទំ ខោ ភន្តេ អាយស្មន្តំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ, បដិគ្គណ្ហាតុ អាយស្មា ចីវរចេតាបន"ន្តិ ។ តេន ភិក្ខុនា សោ ទូតោ ឯវមស្ស វចនីយោ "ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយ"ន្តិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឯវំ វទេយ្យ "អត្ថិ បនាយស្មតោ កោចិ វេយ្យាវច្ចករោ"តិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ និទ្ទិសិតព្វោ អារាមិកោ វា ឧបាសកោ វា "ឯសោ ខោ អាវុសោ ភិក្ខូនំ វេយ្យាវច្ចករោ"តិ ។ សោ ចេ ទូតោ តំ វេយ្យាវច្ចករំ សញ្ញាបេត្វា តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ "យំ ខោ ភន្តេ អាយស្មា វេយ្យាវច្ចករំ និទ្ទិសិ, សញ្ញត្តោ សោ មយា, ឧបសង្កមតុ អាយស្មា កាលេន, ចីវរេន តំ អច្ឆាទេស្សតី"តិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ ឧបសង្កមិត្វា ទ្វិត្តិក្ខត្តុំ ចោទេតព្វោ សារេតព្វោ "អត្ថោ មេ អាវុសោ ចីវរេនា"តិ ទ្វិត្តិក្ខត្តុំ ចោទយមានោ សារយមានោ តំ ចីវរំ អភិនិប្ផាទេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ អភិនិប្ផាទេយ្យ, ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ, ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតោ ឧទ្ទិស្ស តិដ្ឋមានោ តំ ចីវរំ អភិនិប្ផាទេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ អភិនិប្ផាទេយ្យ តតោ ចេ

**ឧត្តរឹ វាយមមានោ តំ ចីវរំ អភិនិប្ផាទេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ នោ ចេ អភិនិប្ផាទេយ្យ, យតស្ស ចីវរចេតាបន្នំ អាភតំ, តត្ថ សាមំ វា គន្តព្វំ, ទូតោ វា បាហេតព្វោ "យំ ខោ តុម្ហេ អាយស្មន្តោ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបន្នំ បហិណិត្ថ, ន តំ តស្ស ភិក្ខុនោ កិញ្ចិ អត្ថំ អនុភោតិ ,យុញ្ជន្តាយស្មន្តោ សកំ, មា វោ សកំ វិនស្សា"តិ, អយំ តត្ថ សាមីចិ ។**

ស្តេចក្តី រាជអាមាត្យក្តី ព្រាហ្មណ៍ក្តី គហបតីក្តី បញ្ជូនតម្លៃចីវរទៅដោយបម្រើចំពោះភិក្ខុ ១ រូបថា អ្នកឯងចូរទិញចីវរដោយតម្លៃចីវរនេះ ហើយចូរឱ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចុះ ។ បើបម្រើនោះ ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា លោកម្ចាស់ តម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ លោកដ៏មានអាយុសូមទទួលយកតម្លៃចីវរចុះ ។ ភិក្ខុនោះត្រូវនិយាយពាក្យយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ ។ បើបម្រើនោះពោលនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយជាវេយ្យាវច្ចករ របស់លោកដ៏មានអាយុ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសកថា ម្នាលអាវុសោ អ្នកនេះឯងជាវេយ្យាវច្ចករ របស់ភិក្ខុទាំងឡាយ ។ បើបម្រើនោះ ពន្យល់វេយ្យាវច្ចករនោះហើយ ក៏ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុបង្ហាញវេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបានពន្យល់ហើយ សូមលោកដ៏មានអាយុ ចូលទៅរក (គេ) ចុះ គេនឹងឱ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរ ដោយកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីចូលទៅតឹងទារ ដាស់តឿនវេយ្យាវច្ចករពីរ បីលើកថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ កាលបើភិក្ខុទៅតឹងទារ ទៅដាស់តឿនអស់

ពីរបីលើក ក៏ញុំាងចីវរនោះឱ្យសម្រេចបាន ការនេះ ជាការល្អ បើញុំាងចីវរនោះ ឱ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅឈរស្ងៀមចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក យ៉ាងច្រើន កាលបើភិក្ខុឈរស្ងៀមនៅចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក យ៉ាងច្រើន ញុំាងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ បើធ្វើចីវរនោះឱ្យសម្រេចមិនបានទេ ហើយភិក្ខុនោះចេះតែព្យាយាមឱ្យលើសអំពីកំណត់នោះទាល់តែបានចីវរនោះមក ភិក្ខុនោះត្រូវនិស្សគ្គិយបាចិត្តិយ បើភិក្ខុញុំាងចីវរនោះឱ្យសម្រេចមិនបានទេ បម្រើនោះនាំតម្លៃចីវរមកដើម្បីភិក្ខុនោះ អំពីសំណាក់អ្នកណា ភិក្ខុគប្បីទៅខ្លួនឯង ឬប្រើបម្រើទៅ ក្នុងសំណាក់អ្នកនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរណា ទៅចំពោះភិក្ខុរូបណា តម្លៃចីវរនោះមិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុរូបនោះទេ អ្នកដ៏មានអាយុ ចូរទារយករបស់ខ្លួនវិញចុះ ទ្រព្យរបស់អ្នកទាំងឡាយ ចូរកុំឱ្យវិនាស ការនេះជាសាមីចិកម្ម (សេចក្តីប្រព្រឹត្តិគួរ) ក្នុងសិក្ខាបទនោះ ។

## ចប់ចីវរវគ្គ ទី ១

# កោសិយវគ្គទី២

## [៣០] កោសិយ សិក្ខាបទទី ១

សិក្ខាបទ ការធ្វើសន្ថ័តដោយរោមចៀមលាយសូត្រ

(បិដក.៣.៨៩)

**យោ បន ភិក្ខុ កោសិយមិស្សកំ សន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយ ឱ្យគេធ្វើសន្ថ័តលាយដោយសូត្រ សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣១] សុទ្ធកាឡក សិក្ខាបទទី ២

សិក្ខាបទ ការធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ

(បិដក.៣.៩២)

**យោ បន ភិក្ខុ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយ ឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

## [៣២] ទ្វេភាគ សិក្ខាបទទី ៣

សិក្ខាបទ ការធ្វើសន្ថ័តយករោមចៀមខ្មៅពីរភាគមកលាយ

(បិដក.៣.៩៤)

**នវំ បន ភិក្ខុនា សន្ថតំ ការយមានេន ទ្វេ ភាគា សុទ្ធកាឡកានំ ឯឡកលោមានំ អាទាតព្វា, តតិយំ ឱទាតានំ, ចតុត្ថំ គោចរិយានំ ។ អនាទា ចេ ភិក្ខុ ទ្វេ ភាគេ សុទ្ធកាឡកានំ ឯឡកលោមានំ តតិយំ ឱទាតានំ, ចតុត្ថំ គោចរិយានំ នវំ សន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុកាលឱ្យគេធ្វើសន្ថ័តថ្មី គប្បីកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមស ភាគទីបី (១ភាគ) រោមចៀមក្រហមភាគទីបួន (១ភាគ) ។ បើភិក្ខុឱ្យគេធ្វើសន្ថ័តថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទីបី រោមចៀមក្រហមភាគទីបួន ទេ សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៣] **ឆព្វស្ស សិក្ខាបទទី ៤**

សិក្ខាបទ ការធ្វើសន្ថ័តថ្មីហើយត្រូវប្រើប្រាស់ឱ្យបាន ៦ ឆ្នាំ

(បិដក.៣.១០២)

**នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ, ឱរេន ចេ ឆន្នំ វស្សានំ តំ សន្ថតំ វិស្សជ្ជេត្វា វា អវិស្សជ្ជេត្វា វា អញ្ញំ នវំ សន្ថតំ ការាបេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា,និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុឱ្យគេធ្វើសន្ថ័តថ្មីគប្បីប្រើប្រាស់ឱ្យបាន ៦ ឆ្នាំ ។ បើមិនទាន់បាន ៦ ឆ្នាំទេ លះចោលសន្ថ័តនោះក្តី មិនលះចោលក្តី ហើយឱ្យគេធ្វើសន្ថ័តថ្មីដទៃទៀត វៀរលែងតែភិក្ខុបានសម្មតិ (អំពីសង្ឃ) សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៤] **និសីទនសន្ថត សិក្ខាបទទី ៥**

សិក្ខាបទ ការធ្វើនិសីទនៈ ត្រូវកាត់យកសន្ថ័តចាស់មកលាយ

(បិដក.៣.១១២)

**និសីទនសន្ថតំ បន ភិក្ខុនា ការយមានេន បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថិ អាទាតព្វា ទុព្វណ្ណករណាយ ។ អនាទា ចេ ភិក្ខុ បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ, នវំ និសីទនសន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុកាលឱ្យគេធ្វើសន្ថតសម្រាប់អង្គុយ គប្បីយកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹងសន្ថតថ្មី) ដើម្បីនឹងធ្វើសន្ថតថ្មីនោះឱ្យខូចពណ៌ ។ បើភិក្ខុឱ្យគេធ្វើនិសីទនសន្ថតថ្មី មិនយកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹងសន្ថតថ្មីទេ) សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៥] ឯឡកលោម សិក្ខាបទទី ៦

សិក្ខាបទ ការកាន់យករោមចៀមដើរបានត្រឹម ៣ យោជន៍

(បិដក.៣.១១៦)

**ភិក្ខុនោ បនេវ អទ្ធានមគ្គប្បដិបន្នស្ស ឯឡកលោមានិ ឧប្បជ្ជេយ្យុំ, អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វានិ, បដិគ្គហេត្វា តិយោជនបរមំ សហត្ថា ហារេតព្វានិ អសន្តេ ហារកេ ។ តតោ ចេ ឧត្តរឹ ហរេយ្យ, អសន្តេបិ ហារកេ, និស្សគ្គិយំ បាចិត្តិយំ ។**

រោមចៀមទាំងឡាយកើតឡើងដល់ភិក្ខុអ្នកដើរផ្លូវឆ្ងាយ កាលបើភិក្ខុប្រាថ្នា គប្បីទទួលយកបាន លុះទទួលហើយ បើមិនមានអ្នកនាំយកទៅទេ គប្បីនាំយកទៅដោយដៃខ្លួនឯង កាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹម ៣ យោជន៍ កាលបើមិនមានអ្នកនាំយកទៅឱ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯង លើសពីកំណត់នោះទៅ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៦] ឯឡកលោមធោវាបន សិក្ខាបទទី ៧

សិក្ខាបទ ការប្រើភិក្ខុនីឱ្យលាងជ្រលក់គក់រោមចៀម

(បិដក.៣.១២២)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ឯឡកលោមានិ ធោវាបេយ្យ វា រជាបេយ្យ វា វិជដាបេយ្យ វា, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយប្រើនាងភិក្ខុនីមិនមែនជាញាតិ ឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យសិតក្តី ឬ ត្រដោះក្តី នូវរោមចៀមទាំងឡាយ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៧] រូបិយ សិក្ខាបទទី ៨

សិក្ខាបទ ការទទួលរូបិយ

(បិដក.៣.១២៨)

**យោ បន ភិក្ខុ ជាតរូបរជតំ ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា ឧបនិក្ខិត្តំ វា សាទិយេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយ ទទួលខ្លួនឯងក្តី ប្រើគេឱ្យទទួលក្តី នូវមាសប្រាក់ ឬមួយត្រេកអរនូវមាសប្រាក់ ដែលគេទុកដាក់ឱ្យ មាសប្រាក់នោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៨] រូបិយសំវោហារ សិក្ខាបទទី ៩

សិក្ខាបទ ការលក់ទិញដោយរូបិយ

(បិដក.៣.១៣៤)

**យោ បន ភិក្ខុ នានប្បការកំ រូបិយសំវោហារំ សមាបជ្ជេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយប្រព្រឹត្តទិញដូរដោយរូបិយ មានប្រការផ្សេង ៗ វត្ថុដែលទិញមកនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៣៩] កយវិក្កយ សិក្ខាបទទី ១០

សិក្ខាបទ ការទិញផ្លាស់ប្តូរដោយអប្បិយវត្ថុ

(បិដក.៣.១៤១)

**យោ បន ភិក្ខុ នានប្បការកំ កយវិក្កយំ សមាបជ្ជេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយប្រព្រឹត្តទិញដូររបស់មានប្រការផ្សេងៗ របស់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## ចប់កោសិយវគ្គទី ២

# បត្តវគ្គទី ៣

## [៤០] បត្ត សិក្ខាបទទី ១

សិក្ខាបទ ការទុកអតិរេកបាត្រ

(បិដក.៣.១៤៧)

**ទសាហបរមំ អតិរេកបត្តោ ធារេតព្វោ, ។ តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ ។**

អតិរេកបាត្រភិក្ខុទ្រទ្រង់ទុក បានត្រឹមកំណត់ ១០ ថ្ងៃ កន្លងហួសអំពីនោះទៅ អតិរេកបាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

## [៤១] ឩនបញ្ចពន្ធន សិក្ខាបទទី ២

សិក្ខាបទ ការមានបាត្រដែលមិនទាន់មានចំណងគ្រប់ ៥ អន្លើ

(បិដក.៣.១៥៧)

**យោ បន ភិក្ខុ ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ, ។ តេន ភិក្ខុនា សោ បត្តោ ភិក្ខុបរិសាយ និស្សជ្ជិតព្វោ, យោ ច តស្សា ភិក្ខុបរិសាយ បត្តបរិយន្តោ, សោ ច តស្ស ភិក្ខុនោ បទាតព្វោ "អយន្តេ ភិក្ខុ បត្តោ យាវ ភេទនាយ ធារេតព្វោ"តិ, អយំ តត្ថ សាមីចិ ។**

ភិក្ខុណាមួយមានបាត្រមិនទាន់មានចំណងគ្រប់ ៥ អន្លើ ឱ្យគេរកបាត្រថ្មីទៀត (បាត្រនោះ) ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តយ ។ ភិក្ខុនោះ ត្រូវលះបង់បាត្រនោះ ក្នុងភិក្ខុបរិស័ទ ។ បាត្រណាជាទីបំផុតរបស់ភិក្ខុបរិស័ទនោះ បាត្រនោះ ភិក្ខុដែលបានសន្មតត្រូវប្រគល់បាត្រនោះ ឱ្យដល់ភិក្ខុនោះដោយពាក្យថា ម្នាលភិក្ខុ នេះបាត្ររបស់លោក ៗ គប្បីប្រើប្រាស់ត្រាតែបែក ។ នេះជាសាមីចិកម្ម ( គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ ។

## [៤២] ភេសជ្ជ សិក្ខាបទទី ៣

សិក្ខាបទ ការទុកភេសជ្ជៈបានប្រាំពីរថ្ងៃ

(បិដក.៣.១៧៥)

**យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ។ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ, តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ ។**

ភេសជ្ជៈណាមួយដែលពួកភិក្ខុមានជំងឺ គប្បីឆាន់បាន ភេសជ្ជៈនេះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ បើភិក្ខុទុកឱ្យកន្លងកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៣] វស្សិកសាដិកចីវរ សិក្ខាបទទី ៤

សិក្ខាបទ ការស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង

(បិដក.៣.១៨០)

**មាសោ សេសោ គិម្ហានន្តិ ភិក្ខុនា វស្សិកសាដិកចីវរំ បរិយេសិតព្វំ, អឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតព្វំ ។ ឱរេន ចេ "មាសោ សេសោ គិម្ហានន្តិ វស្សិកសាដិកចីវរំ បរិយេសេយ្យ ឱរេន"ឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុកំណត់ដឹងថា ខែមួយជាខាងចុងនៃគិម្ហរដូវ គប្បីស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ភិក្ខុកំណត់ដឹងថា នៅកន្លះខែជាខាងចុងនៃគិម្ហរដូវទៀត គប្បីធ្វើឱ្យស្រេចហើយប្រើប្រាស់ចុះ ។ បើមិនទាន់ដល់ ខែ ១ ជាខាងចុងនៃគិម្ហរដូវទេ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង និងមិន

ទាន់ដល់កន្លះខែជាខាងចុងនៃគិម្ហរដូវទេ ភិក្ខុធ្វើឱ្យសម្រេចហើយប្រើប្រាស់ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៤] **អច្ឆិន្ទន សិក្ខាបទទី ៥**

សិក្ខាបទ ការឱ្យចីវរហើយដណ្តើមយកមកវិញ

(បិដក.៣.១៨៧)

**យោ បន ភិក្ខុ ភិក្ខុស្ស សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយឱ្យចីវរដល់ភិក្ខុ (ដទៃ) ដោយខ្លួនឯងហើយ ខឹងអន់ចិត្តដណ្តើមយក (ចីវរ) មកវិញក្តី ប្រើឱ្យគេដណ្តើមយកមកវិញក្តី ភិក្ខុនោះត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៥] **សុត្តវិញ្ញត្តិ សិក្ខាបទទី ៦**

សិក្ខាបទ ការសូមនូវអំបោះឱ្យជាងត្បាញចីវរ

(បិដក.៣.១៩១)

**យោ បន ភិក្ខុ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយ សូមអំបោះមកដោយខ្លួនឯង ហើយឱ្យពួកជាងតម្បាញត្បាញចីវរឱ្យ ភិក្ខុនោះត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៦] **មហាបេសការ សិក្ខាបទទី ៧**

សិក្ខាបទ ការប្រើឱ្យគេត្បាញចីវរ

(បិដក.៣.១៩៨)

**ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកោ គហបតិ វា គហបតានី វា តន្តវាយេហិ ចីវរំ វាយាបេយ្យ, តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ តន្តវាយេ**

**ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ "ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ, អាយតញ្ច ករោថ, វិត្ថតញ្ច អប្បិតញ្ច សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច ករោថ, អប្បេវ នាម មយម្បិ អាយស្មន្តានំ កិញ្ចិ មត្តំ អនុបទជ្ជេយ្យាមាតិ ។ ឯវញ្ច សោ ភិក្ខុ វត្វា កិញ្ចិ មត្តំ អនុបទជ្ជេយ្យ អន្តមសោ បិណ្ឌបាតមត្តម្បិ, និស្សគ្គិយំ បាចិត្តិយំ ។**

គហបតី (គឺបុរសជាម្ចាស់ផ្ទះ)ក្តី គហបតានី (គឺស្រីជាម្ចាស់ផ្ទះ)ក្តី ដែលមិនមែនជាញាតិ ឱ្យជាងតម្បាញត្បាញចីវរចំពោះភិក្ខុណាមួយ ។ បើភិក្ខុនោះ ដែលអ្នកម្ចាស់ចីវរគេមិនបានបវារណាមកពីកាលមុនក្នុងរឿងចីវរនោះ អាចហ៊ានចូលទៅរកជាងតម្បាញ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺ រិះគិតចង់បានល្អឱ្យហួសហេតុ) គឺពោលថា នែអ្នកដ៏មានអាយុ ចីវរនេះ គេឱ្យត្បាញចំពោះអាត្មា អ្នកទាំងឡាយចូរធ្វើឱ្យវែង ឱ្យទូលាយ ឱ្យមានសាច់ញឹក ឱ្យស្មើល្អ រឹតឱ្យតឹងល្អ ចូរត្រដោះកួតហើយសិតឱ្យល្អ សឹមអាត្មា ថែមរង្វាន់ឱ្យអ្នកបន្តិចបន្តួច ។ ភិក្ខុនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឱ្យ ដោយហោចទៅទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត (មួយឆ្នែត) ក៏ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៧] អច្ចេកចីវរ សិក្ខាបទទី ៨

សិក្ខាបទ ការទទួលអច្ចេកចីវរទុក

(បិ៩ក.៣.២០៩)

**ទសាហានាគតំ កត្តិកតេមាសិបុណ្ណមំ ភិក្ខុនោ បនេវ អច្ចេកចីវរំ ឧប្បជ្ជេយ្យ, អច្ចេកំ មញ្ញមានេន ភិក្ខុនា បដិគ្គហេតព្វំ, បដិគ្គហេត្វា យាវចីវរកាលសមយំ និក្ខិបិតព្វំ ។ តតោ ចេ ឧត្តរី និក្ខិបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។**

ថ្ងៃពេញបូណ៌មីខែកត្តិក ដែលជាខែទី ៣ នៃវស្សានរដូវនៅខ្វះ ១០ ថ្ងៃទៀតនឹងគ្រប់ (គឺថ្ងៃ ៥ កើតខែអស្សុជ) បើអច្ចេកចីវរកើតឡើងដល់ភិក្ខុ ៗ សម្គាល់

ថា ជាអច្ចេកចីវរ គប្បីទទួលទុកលុះទទួលហើយ គប្បីទុកដាក់ដរាបអស់សម័យចីវរកាល បើភិក្ខុទុកយូរឱ្យហួសកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

## [៤៨] សាសង្ក សិក្ខាបទទី ៩

សិក្ខាបទ ការនៅក្នុងព្រៃដែលគេសន្មតថាជាទីមានសេចក្ដីរង្កៀស
(បិដក.៣.២១១)

**ឧបវស្សំ ខោ បន កត្តិកបុណ្ណមំ, យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ អាកង្ខមានោ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបេយ្យ ។ សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ តេន ចីវរេន វិប្បវាសាយ, ឆារត្តបរមន្តេ ភិក្ខុនា តេន ចីវរេន វិប្បវសិតព្វំ ។ តតោ ចេ ឧត្តរឹ វិប្បវសេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។**

កាលបើភិក្ខុទាំងឡាយចាំវស្សារួចហើយ លុះដល់មកពេញបូណ៌មីខែកត្តិក ។ សេនាសនៈទាំងឡាយណា ដែលតាំងនៅក្នុងព្រៃ ដែលគេសម្មតិថា ជាទីមានសេចក្ដីរង្កៀស មានភ័យចំពោះមុខ កាលភិក្ខុនៅក្នុងសេនាសនទាំងឡាយមានសភាពដូច្នោះ បើមានចំណង់នឹងទុកចីវរ គប្បីទុកបណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះ ។ តែបើភិក្ខុនោះ មានហេតុអ្វីនីមួយល្មមឱ្យនៅប្រាសចាកចីវរនោះបាន ភិក្ខុនោះគប្បីនៅប្រាសចាកចីវរនោះ យ៉ាងយូរត្រឹម ៦ រាត្រី បើនៅប្រាសចាកឱ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុបានសេចក្ដីសម្មតិអំពីសង្ឃ ។

## [៤៩] បរិណត សិក្ខាបទទី ១០

សិក្ខាបទ ការបង្អោនលាភរបស់សង្ឃ

(បិដក.៣.២១៧)

**យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹង ហើយបង្អោននូវលាភរបស់សង្ឃ ដែលគេនឹងបង្អោនទៅ (ដើម្បីសង្ឃ) មកដើម្បីខ្លួនវិញ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

**ចប់បត្តវគ្គទី ៣**

**ចប់និស្សគ្គិយ បាចិត្តិយកណ្ឌ**

# បាចិត្តិយកណ្ឌ

## មុសាវាទវគ្គ

### [៥០] មុសាវាទ សិក្ខាបទទី ១

សិក្ខាបទ ការពោលពាក្យកុហក

(បិដក.៣.២២៣)

**សម្បជានមុសាវាទេ បាចិត្តិយំ ។** ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

### [៥១] ឱមសវាទ សិក្ខាបទទី ២

សិក្ខាបទ ការពោលពាក្យអាក្រក់ (ជេរ)

(បិដក.៣.២៤០)

**ឱមសវាទេ បាចិត្តិយំ** ។ ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិបាចិត្តិយ ។

### [៥២] បេសុញ្ញវាទ សិក្ខាបទទី ៣

សិក្ខាបទ ការពោលពាក្យញុះញង់

(បិដក.៣.២៧៤)

**ភិក្ខុបេសុញ្ញេ បាចិត្តិយំ** ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា ។

### [៥៣] បទសោធម្ម សិក្ខាបទទី ៤

សិក្ខាបទ ការបង្រៀនធម៌បទ

(បិដក.៣.២៨៦)

**យោ បន ភិក្ខុ អនុបសម្បន្នំ បទសោ ធម្មំ វាចេយ្យ, បាចិត្តិយំ** ។ ភិក្ខុណាមួយបង្រៀនធម៌ជាបទ ចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ។

## [៥៤] បឋមសហសេយ្យ សិក្ខាបទទី ៥

សិក្ខាបទ ការដេករួមជាមួយអនុបសម្បន្ន

(បិដក.៣.២៩២)

**យោ បន ភិក្ខុ អនុបសម្បន្នេន ឧត្តរិទ្វិរត្តតិរត្តំ សហសេយ្យំ កប្បេយ្យ, បាចិត្តិយំ។**

ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាង ពីរ យប់ ឬ បី យប់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [៥៥] ទុតិយសហសេយ្យ សិក្ខាបទទី ៦

សិក្ខាបទ ការដេករួមជាមួយមាតុគ្រាម

(បិដក.៣.៣០០)

**យោ បន ភិក្ខុ មាតុគ្គាមេន សហសេយ្យំ កប្បេយ្យ បាចិត្តិយំ។**

ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

## [៥៦] ធម្មទេសនា សិក្ខាបទទី ៧

សិក្ខាបទ ការសម្តែងធម៌ដល់មាតុគ្រាម

(បិដក.៣.៣០៨)

**យោ បន ភិក្ខុ មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេយ្យ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន បាចិត្តិយំ ។**

ភិក្ខុណាមួយ សម្តែងធម៌ដល់មាតុគ្រាមលើសពីប្រាំមាត់ឬប្រាំមួយមាត់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានបុរសដែលដឹងក្តី (អង្គុយជិត ) ។

## [៥៧] ភូតារោចន សិក្ខាបទ ទី ៨

សិក្ខាបទ ការប្រាប់គុណវិសេសដែលមានពិត

(បិដក.៣.៣១៧)

**យោ បន ភិក្ខុ អនុបសម្បន្នស្ស ឧត្តរិមនុស្សធម្មំ អារោចេយ្យ ភូតស្មឹ បាចិត្តិយំ ។**

ភិក្ខុណាមួយប្រាប់ឧត្តរិមនុស្សធម៌ ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះឧត្តរិមនុស្សធម៌នោះភិក្ខុបានពិតមែន ។

## [៥៨] ទុដ្ឋុល្លារោចន សិក្ខាបទ ទី ៩

សិក្ខាបទ ការប្រាប់អាបត្តិអាក្រក់

(បិដក.៣.៣៣៨)

**យោ បន ភិក្ខុ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេយ្យ អញ្ញត្រ ភិក្ខុសម្មុតិយា,បាចិត្តិយំ។**

ភិក្ខុណាមួយ ប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឱ្យប្រាប់ ។

## [៥៩] បឋវីខណន សិក្ខាបទ ទី ១០

សិក្ខាបទ ការទម្លាយផែនដី

(បិដក.៣.២៤៣)

**យោ បន ភិក្ខុ បឋវឹ ខណេយ្យ វា ខណាបេយ្យ វា បាចិត្តិយំ ។**

ភិក្ខុណាមួយ ជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី នូវផែនដី ត្រូវអាបត្តិបាចិត្តិយ ។

## ចប់មុសាវាទវគ្គ ទី ១

## ភូតគាមវគ្គ ទី ២

### [៦០] ភូតគាម សិក្ខាបទទី ១១

សិក្ខាបទ ការញុំាងភូតគាមឱ្យវិនាស

(បិ.៣.៣៤៩)

**ភូតគាមបាតព្យតាយ បាចិត្តិយំ ។** ភិក្ខុធ្វើភូតគាម មានឈើនឹងស្មៅជាដើម ឱ្យវិនាស ត្រូវអាបត្តិបាចិត្តិ ។

### [៦១] អញ្ញវាទក សិក្ខាបទទី ១២

សិក្ខាបទ ការពោលពាក្យដទៃឱ្យសង្ឃលំបាក

(បិ.៣.៣៥៨)

**អញ្ញវាទកេ, វិហេសកេ បាចិត្តិយំ ។** ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ (ឬ) ព្រោះធ្វើឱ្យសង្ឃបានសេចក្ដីលំបាក ។

### [៦២] ឧជ្ឈាបន សិក្ខាបទទី ១៣

សិក្ខាបទ ការពោលទោសអ្នកដទៃ

(បិ.៣.៣៦៤)

**ឧជ្ឈាបនកេ ខីយនកេ បាចិត្តិយំ ។** ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោលទោស (ភិក្ខុផងគ្នា) ឬតិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ ។

## [៦៣] បឋមសេនាសន សិក្ខាបទទី ១៤

សិក្ខាបទ ការទុកដាក់សេនាសនៈទី១

(បិ.៣.៣៦៩)

**យោ បន ភិក្ខុ សង្ឃិកំ មញ្ចំ វា បីឋំ វា ភិសឹ វា កោច្ឆំ វា អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ, ន ឧទ្ធរាបេយ្យ, អនាបុច្ឆំ វា គច្ឆេយ្យ,បាចិត្តិយំ ។**

ភិក្ខុណាមួយលាតឬសន្ទឹងខ្លួនឯងក្តី ឱ្យគេលាតក្តី នូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរចេញទៅមិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះ មកទុកដាក់ឯង មិនបានប្រើគេឱ្យរើយកមកទុកដាក់ ហើយឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

## [៦៤] ទុតិយសេនាសនសិក្ខាបទទី ១៥

សិក្ខាបទ ការទុកដាក់សេនាសនៈទី២

(បិ.៣.៣៧៦)

**យោ បន ភិក្ខុ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ, ន ឧទ្ធរាបេយ្យ, អនាបុច្ឆំ វា គច្ឆេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយ ក្រាលឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃហើយ កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

## [៦៥] អនុប្បខជ្ជ សិក្ខាបទទី ១៦

សិក្ខាបទ ការចូលទៅច្រៀតបៀត

(បិ. ៤. ២.)

**យោ បន ភិក្ខុ សង្ឃិកេ វិហារេ ជានំ បុព្ពុបគតំ ភិក្ខុំ អនុប្បខជ្ជ សេយ្យំ កប្បេយ្យ "យស្ស សម្ពាធោ ភវិស្សតិ, សោ បក្កមិស្សតី"តិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ។**

ភិក្ខុណាមួយ ដឹងហើយចូលទៅច្រៀតបៀតនូវភិក្ខុដែលចូលទៅនៅមុន ហើយសម្រេចនូវទីដេក ក្នុងវិហាររបស់សង្ឃដោយគិតថា ភិក្ខុណាមានសេចក្ដីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវសេចក្ដីច្រៀតបៀតនោះឯងឱ្យជាបច្ច័យ មិនមែនហេតុដទៃទេ ។

## [៦៦] និកឌ្ឍន សិក្ខាបទទី ១៧

សិក្ខាបទ ការទង់ទាញឱ្យចេញ

(បិ. ៤. ៧.)

**យោ បន ភិក្ខុ ភិក្ខុំ កុបិតោ អនត្តមនោ សង្ឃិកា វិហារា និក្កឌ្ឍេយ្យ វា និក្កឌ្ឍាបេយ្យ វា បាចិត្តិយំ ។**

ភិក្ខុណាមួយ មានចិត្តក្រោធខឹងនឹងភិក្ខុផងគ្នា ហើយទង់ទាញឯងក្ដី ប្រើគេឱ្យទង់ទាញក្ដី ចេញចាកវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

## [៦៧] វេហាសកុដិ សិក្ខាបទទី ១៨

សិក្ខាបទ ការអង្គុយឬដេកលើគ្រែឬតាំងលើកុដិថ្នាក់ខាងលើ

(បិ. ៤. ១២.)

**យោ បន ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា, បាចិត្តិយំ ។**

ភិក្ខុណាមួយអង្គុយចុះ ដោយរហ័សសង្កត់ ឬដេកសង្កត់នូវគ្រែក្តី នូវតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) លើថ្នាក់ក្នុងវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

## [៦៨] មហល្លកវិហារ សិក្ខាបទទី ១៩

សិក្ខាបទ ការប្រក់បូកវិហារធំ(បិ.៤.១៦.)

**មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន យាវ ទ្វារកោសា អគ្គឡដ្ឋបនាយ អាលោកសន្ធិបរិកម្មាយ ទ្វិត្តិច្ឆទនស្ស បរិយាយំ អប្បហរិតេ ឋិតេន អធិដ្ឋាតព្វំ, តតោ ចេ ឧត្តរឹ អប្បហរិតេបិ ឋិតោ អធិដ្ឋហេយ្យ, បាចិត្តិយំ ។**

ភិក្ខុកាលឱ្យគេធ្វើវិហារធំ គប្បីឈរ (លាបបូកញយ ៧ បាន) កំណត់ទីមានឱកាសត្រឹមតែសន្លឹកទ្វារ (នឹងសន្លឹកបង្អួច) ដើម្បីទុកប្រើប្រាស់នូវទ្វារនឹងដើម្បីបរិកម្មនូវសន្លឹកបង្អួច ឯដំបូលភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ (នោះទើប) ប្រក់បានត្រឹមពីរឬបីជាន់ បើភិក្ខុប្រក់ឱ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ ក៏គង់ត្រូវអាបត្តិបាចិត្តិយ ។

## [៦៩] សប្បាណក សិក្ខាបទទី ២០

សិក្ខាបទ ការចាក់ (ប្រើ) ទឹកដែលមានសត្វ
(បិ.៤.២១.)

**យោ បន ភិក្ខុ ជានំ សប្បាណកំ ឧទកំ តិណំ វា មត្តិកំ វា សិញ្ចេយ្យ វា សិញ្ចាបេយ្យ វា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ដឹងថាទឹកមានសត្វហើយស្រោចឯងក្តី ប្រើគេឱ្យស្រោច នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ ។

## ចប់ភូតគាមវគ្គទី ២

# ឱវាទវគ្គទី ៣

## [៧០] ឱវាទ សិក្ខាបទទី ២១

សិក្ខាបទ ការបង្រៀនប្រដៅភិក្ខុនី

( បិ. ៤. ២៧.)

**យោ បន ភិក្ខុ អសម្មតោ ភិក្ខុនិយោ ឱវទេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ ដែលសង្ឃមិនបានសន្មត ហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។

## [៧១] អដ្ឋង្គត សិក្ខាបទទី២២

សិក្ខាបទ ការប្រដៅភិក្ខុនីក្នុងកាលអស្តង្គត

( បិ. ៤. ៤២.)

**សម្មតោបិ ចេ ភិក្ខុ អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយំ ។**

ភិក្ខុបើទុកជាសង្ឃ បានសន្មតហើយ កាលបើព្រះអាទិត្យអស្តង្គតហើយ ទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។

## [៧២] ភិក្ខុនីឧបស្សយ សិក្ខាបទទី២៣

សិក្ខាបទ ការចូលទៅប្រដៅភិក្ខុនីក្នុងលំនៅ

( បិ. ៤. ៤៧.)

**យោ បន ភិក្ខុ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ, គិលានា ហោតិ ភិក្ខុនី, អយំ តត្ថ សមយោ ។**

ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនីហើយប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុនីមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។

## [៧៣] **អាមិស សិក្ខាបទទី ២៤**

សិក្ខាបទ ការប្រដៅភិក្ខុនីព្រោះហេតុតែអាមិស

(បិ.៤.៩១.)

**យោ បន ភិក្ខុ ឯវំ វទេយ្យ "អាមិសហេតុ ភិក្ខូ ភិក្ខុនិយោ ឱវទន្តី"តិ បាចិត្តិយំ ។**

ភិក្ខុណាមួយ ពោលយ៉ាងនេះថា ភិក្ខុទាំងឡាយ ប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ត្រូវអាបត្តិបាចិត្តិយ ។

## [៧៤] **ចីវរទានសិក្ខាបទទី ២៥**

សិក្ខាបទ ការឱ្យចីវរដល់ភិក្ខុនីមិនមែនញាតិ

(បិ.៤.៩៦.)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទទេយ្យ អញ្ញត្រ បារិវដ្ដកា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ឱ្យចីវរដល់ភិក្ខុនី មិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ វៀរតែផ្លាស់ប្ដូរគ្នា ។

## [៧៥] **ចីវរសិព្វន សិក្ខាបទទី ២៦**

សិក្ខាបទ ការដេរចីវរឱ្យភិក្ខុនីមិនមែនញាតិ

(បិ.៤.៦១.)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វេយ្យ វា សិព្វាបេយ្យ វា បាចិត្តិយំ ។**

ភិក្ខុណាមួយ ដេរឯង ឬប្រើគេឱ្យដេរនូវចីវរឱ្យភិក្ខុនីមិនមែនញាតិ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

## [៧៦] សំវិធាន សិក្ខាបទទី ២៧

សិក្ខាបទ ការបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយ

(បិ.៤.៦៥.)

**យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ គាមន្តរម្បិ អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ, សត្ថគមនីយោ ហោតិ មគ្គោ, សាសង្កសម្មតោ, សប្បដិភយោ, អយំ តត្ថ សមយោ ។**

ភិក្ខុណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយ ជាមួយគ្នាដោយហោចទៅសូម្បីទៅកាន់ទីជាលង្វែកនៃស្រុក ១ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺផ្លូវដែលគួរនឹងទៅដោយមានគ្នីគ្នាជាពួក ១ ដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀស ១ ដែលប្រកបដោយភ័យចំពោះមុខ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

## [៧៧] នាវាភិរូហន សិក្ខាបទទី ២៨

សិក្ខាបទ ការបបួលភិក្ខុនីឡើងជិះទូក

(បិ.៤.៧១.)

**យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកនាវំ អភិរូហេយ្យ ឧទ្ធំគាមិនឹ វា អធោគាមិនឹ វា អញ្ញត្រ តិរិយន្តរណាយ, បាចិត្តិយំ ។**

ភិក្ខុណាមួយ បបួលភិក្ខុនីឡើងជិះទូកមួយ ជាមួយគ្នាទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង ។

## [៧៨] បរិបាចន សិក្ខាបទទី ២៩

សិក្ខាបទ ការឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង

(បិ. ៤. ៧៧.)

**យោ បន ភិក្ខុ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជេយ្យ អញ្ញត្រ បុព្វេ គិហិសមារម្ភា, បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន ។

## [៧៩] រហោនិសជ្ជ សិក្ខាបទទី៣០

សិក្ខាបទ ការអង្គុយក្នុងទីស្ងាត់ជាមួយ នឹងភិក្ខុនី

(បិ. ៤. ៨១.)

**យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនី តែម្នាក់នឹងម្នាក់ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

**ចប់ឱវាទវគ្គ ទី៣**

# ភោជនវគ្គទី ៤

## [៨០] អាវសថបិណ្ឌ សិក្ខាបទទី ៣១

សិក្ខាបទ ការឆាន់ចង្ហាន់ក្នុងរោងទាន
(បិ.៤.៨៧.)

**អគិលានេន ភិក្ខុនា ឯកោ អាវសថបិណ្ឌោ ភុញ្ជិតព្វោ ។ តតោ ចេ ឧត្តរិ ភុញ្ជេយ្យ បាចិត្តិយំ ។**

បិណ្ឌបាតក្នុងរោងទាន ភិក្ខុមិនមានជំងឺ ត្រូវឆាន់បានតែម្តង បើឆាន់ឱ្យលើស ពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

## [៨១] គណភោជនសិក្ខាបទទី ៣២

សិក្ខាបទ ការឆាន់គណភោជន(បិ.៤.៩៧.)

**គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អទ្ធានគមនសមយោ នាវាភិរូហនសមយោ, មហាសមយោ, សមណភត្តសមយោ អយំ តត្ថ សមយោ ។**

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនេះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើនូវចីវរ ១ សម័យដែលដើរផ្លូវឆ្ងាយ ១ សម័យដែលឡើងជិះទូក ១ សម័យដែលមានភិក្ខុច្រើនអង្គ ១ សម័យនៃសមណភត្ត ១ នេះជាសម័យក្នុង សិក្ខាបទនោះ ។

# [៨២] បរម្បរភោជនសិក្ខាបទទី ៣៣

សិក្ខាបទ ការឆាន់ភោជនដទៃ(បិ.៤.១០៦.)

**បរម្បរភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ, ចីវរការសមយោ, អយំ តត្ថ សមយោ ។**

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជំងឺ ១ សម័យនៃចីវរទាន ១ សម័យដែលធ្វើនូវចីវរ ១ នេះជាសម័យ ក្នុងសិក្ខាបទនោះ ។

# [៨៣] កាណមាតា សិក្ខាបទទី ៣៤

សិក្ខាបទ ការទទួលនំនិងសដូវ

(បិ.៤. ១១៩.)

**ភិក្ខុំ បនេវ កុលំ ឧបគតំ បូវេហិ វា មន្ថេហិ វា អភិហដ្ឋុំ បវារេយ្យ អាកង្ខមានេន ភិក្ខុនា ទ្វិត្តិបត្តបូរា បដិគ្គហេតព្វា ។ តតោ ចេ ឧត្តរឹ បដិគ្គណ្ហេយ្យ, បាចិត្តិយំ ។ ទ្វិត្តិបត្តបូរេ បដិគ្គហេត្វា តតោ នីហរិត្វា ភិក្ខូហិ សទ្ធឹ សំវិភជិតព្វំ, អយំ តត្ថ សាមីចិ ។**

ជនបវារណានូវភិក្ខុ ដែលចូលទៅកាន់ត្រកូល ដោយនំទាំងឡាយក្តី ដោយសដូវទាំងឡាយក្តី ដើម្បីនាំទៅបាន តាមប្រាថ្នា ។ ភិក្ខុមានសេចក្តីប្រាថ្នា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ ។ បើទទួលឱ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលបានទទួលនំ ឬ សដូវកំណត់ពេញត្រឹមពីរបី បាត្រហើយ ត្រូវនាំចេញអំពីទីនោះមកចែក មួយអន្លើដោយភិក្ខុទាំងឡាយ ការចែកនំ ឬសដូវនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ ។

## [៨៤] បឋមបវារណា សិក្ខាបទទី ៣៥

សិក្ខាបទ ការហាមភោជនហើយឆាន់

(បិ.៤.១២១.)

**យោ បន ភិក្ខុ ភុត្តាវី បវារិតោ អនតិរិត្តំ ខាទនិយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ឆាន់ហើយ បានហាមភោជនហើយ ទំពាស៊ីក្តី ឆាន់ក្តី នូវខាទនីយាហារ ឬភោជនីយាហារ ដែលជាអនតិរិត្ត គឺជាវត្ថុដែលមិនធ្វើវិន័យកម្ម និងមិនមែនសល់អំពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយ ។

## [៨៥] ទុតិយបវារណា សិក្ខាបទទី ៣៦

សិក្ខាបទ ការបង្ខំភិក្ខុដែលហាមភោជន ឱ្យឆាន់

(បិ.៤.១២៧.)

**យោ បន ភិក្ខុ ភិក្ខុំ ភុត្តាវឹ បវារិតំ អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេយ្យ ហន្ទ ភិក្ខុ ខាទ វា ភុញ្ជ វា"តិ ជានំ អាសាទនាបេក្ខោ, ភុត្តស្មឹ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងហើយរំពៃរកទោសនាំភត្តទៅបវារណា បង្ខំភិក្ខុដែលឆាន់ហើយហាមភត្តហើយ ឱ្យទំពាស៊ីក្តី បរិភោគក្តី នូវអនតិរិត្តភោជនដោយពាក្យថា នែភិក្ខុ អ្នកចូរទំពាស៊ីក្តី បរិភោគក្តី ដូច្នេះនិមិត្តតែភិក្ខុនោះឆាន់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

## [៨៦] វិកាលភោជន សិក្ខាបទទី ៣៧

សិក្ខាបទ ការឆាន់ភោជនក្នុងវេលាវិកាល

(បិ.៤.១៣២.)

**យោ បន ភិក្ខុ វិកាលេ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ ។

## [៨៧] សន្និធិការកសិក្ខាបទទី ៣៨

សិក្ខាបទ ការឆាន់ភោជនដែលសន្សំទុក

(បិ.៤.១៣៦)

**យោ បន ភិក្ខុ សន្និធិការកំ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ជាសន្និធិការកៈ គឺវត្ថុដែលខ្លួនទុកដាក់ឱ្យកន្លងរាត្រី ត្រូវអាបត្តិបាចិត្តិយ ។

## [៨៨] បណីតភោជន សិក្ខាបទទី ៣៩

សិក្ខាបទ ការសូមភោជនដ៏ឧត្តម

(បិ.៤.១៤១.)

**យានិ ខោ បន តានិ បណីតភោជនានិ,សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ មច្ឆោ មំសំ ខីរំ ទធិ ។ យោ បន ភិក្ខុ ឯវរូបានិ បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ, បាចិត្តិយំ ។**

ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះដូចម្តេច ភោជនដ៏ទាំងនោះគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹក

ដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយគ្មានជំងឺ សូមភោជនដ៏ឧត្តមទាំងឡាយ មានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។

## [៨៩] **ទន្តបោណ សិក្ខាបទទី៤០**

សិក្ខាបទ ការឆាន់អាហារ ដែលមិនប្រគេនក្រៅពីទឹក និងឈើស្ទន់

(បិ.៤.១៤៦.)

**យោ បន ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហរេយ្យ អញ្ញត្រ ឧទកទន្តបោណា, បាចិត្តិយំ ។**

ភិក្ខុណាមួយ លេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនិងឈើស្ទន់ ។

## **ចប់ភោជនវគ្គទី ៤**

# អចេលកវគ្គទី ៥

## [៩០]អចេលកសិក្ខាបទទី ៤១

សិក្ខាបទ ការឱ្យខាទនីយនិងភោជនីយដល់អចេលកជាដើម

(បិ.៤.១៥៣.)

**យោ បន ភិក្ខុ អចេលកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ ឱ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគដល់អចេលកក្តី បរិព្វាជកក្តី បរិព្វាជកាក្តី ដោយដៃរបស់ខ្លួនត្រូវអាបត្តិបាចិត្តិយ ។

## [៩១] ឧយ្យោជនសិក្ខាបទទី ៤២

សិក្ខាបទ ការបបួលទៅបិណ្ឌបាតហើយបញ្ជូនឱ្យត្រឡប់វិញ

(បិ.៤.១៥៧.)

**យោ បន ភិក្ខុ ភិក្ខុំ ឯវំ វទេយ្យ ឯហាវុសោ, គាមំ វា និគមំ វា បិណ្ឌាយ បវិសិស្សាមា″តិ តស្ស ទាបេត្វា វា អទាបេត្វា វា ឧយ្យោជេយ្យ ″គច្ឆាវុសោ, ន មេ តយា សទ្ធឹ កថា វា និសជ្ជា វា ផាសុ ហោតិ, ឯកកស្ស មេ កថា វា និសជ្ជា វា ផាសុ ហោតី″តិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ។**

ភិក្ខុណាមួយនិយាយនឹងភិក្ខុយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុកឬនិគមដើម្បីបិណ្ឌបាត ហើយឱ្យគេឱ្យ ឬមិនឱ្យគេឱ្យ(អ្វីៗ) ដល់ភិក្ខុនោះ ហើយបញ្ជូនឱ្យត្រឡប់ទៅវិញដោយពាក្យថា នែអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយឬអង្គុយជាមួយនឹងលោកមិនសប្បាយទេ ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវហេតុនុ៎ះឯងឱ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ ។

## [៩២]សភោជនសិក្ខាបទទី ៤៣

សិក្ខាបទ ការអង្គុយក្នុងផ្ទះដែលមានជនតែពីរនាក់

(បិ.៤.១៦៣.)

**យោ បន ភិក្ខុ សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយចូលទៅសម្រេចការអង្គុយនៅ ក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។

## [៩៣] រហោបដិច្ឆន្ន សិក្ខាបទទី៤៤

សិក្ខាបទ ការអង្គុយលើអាសនៈស្ងាត់

(បិ.៤.១៦៦.)

**យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

## [៩៤]រហោនិសជ្ជ សិក្ខាបទទី ៤៥

សិក្ខាបទ ការអង្គុយក្នុងទីស្ងាត់

(បិ.៤.១៧០.)

**យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ មួយអន្លើដោយមាតុគ្រាមតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។

## [៩៥] ចារិត្ត សិក្ខាបទទី ៤៦

### សិក្ខាបទ ការមិនលាហើយទៅកាន់ត្រកូលទាំងឡាយ

(បិ.៤.១៧៩.)

**យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ សន្តំ ភិក្ខុំ អនាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ, ចីវរទានសមយោ, ចីវរការសមយោ, អយំ តត្ថ សមយោ ។**

ភិក្ខុណាមួយ បានទទួលនិមន្តគេជាអ្នកមានភត្ត ហើយមិនបានលាឬប្រាប់ភិក្ខុដែលមាននៅ ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺ កាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

## [៩៦] មហានាម សិក្ខាបទទី ៤៧

### សិក្ខាបទ ការត្រេកអរនឹងបច្ច័យតាមកំណត់នៃការបវារណា

(បិ.៤.១៨៨.)

**អគិលានេន ភិក្ខុនា ចាតុម្មាសប្បច្ចយប្បវារណា សាទិតព្វា អញ្ញត្រ បុនប្បវារណាយ អញ្ញត្រ និច្ចប្បវារណាយ ។ តតោ ចេ ឧត្តរឹ សាទិយេយ្យ បាចិត្តិយំ ។**

ភិក្ខុដែលគ្មានជំងឺត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ បើភិក្ខុត្រេកអរក្រៃលេងជាងនោះទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែគេបានបវារណាថែមទៀត វៀរលែងតែគេបានបវារណាជានិច្ច ។

## [៩៧] ឧយ្យុត្ត សិក្ខាបទទី ៤៨

សិក្ខាបទ ការទៅមើលក្បួនទ័ព

(បិ.៤.១៩៤.)

**យោ បន ភិក្ខុ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆេយ្យ អញ្ញត្រ តថារូបប្បច្ចយា, បាចិត្តិយំ ។**

ភិក្ខុណាមួយ ទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។

## [៩៨] សេនាវាសសិក្ខាបទទី ៤៩

សិក្ខាបទ ការនៅក្នុងលំនៅកងទ័ព

(បិ.៤.១៩៨.)

**សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ សេនំ គមនាយ, ទិរត្តតិរត្តំ តេន ភិក្ខុនា សេនាយ វសិតព្វំ ។ តតោ ចេ ឧត្តរឹ វសេយ្យ បាចិត្តិយំ ។**

បើភិក្ខុនោះមានហេតុអ្វីៗ គួរនឹងទៅកាន់កងទ័ពនោះ ភិក្ខុនោះត្រូវនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី។ បើនៅឱ្យហួសពីកំណត់នោះទៅត្រូវអាបត្តិបាចិត្តិយ ។

## [៩៩] ឧយ្យោធិក សិក្ខាបទទី ៥០

សិក្ខាបទ ការទៅកាន់ទីចម្បាំងជាដើម

(បិ.៤.២០១.)

**ទិរត្តតិរត្តញ្ចេ ភិក្ខុ សេនាយ វសមានោ ឧយ្យោធិកំ វា ពលគ្គំ វា សេនាព្យូហំ វា អនីកទស្សនំ វា គច្ឆេយ្យ បាចិត្តិយំ ។**

កាលបើភិក្ខុនៅក្នុងកងទ័ព កំណត់ពីរបីរាត្រីហើយ ទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៅនៃកងទ័ពក្តី ទីសម្រាប់គេចាត់ក្បួនទ័ពក្តី ត្រូវអាបត្តិបាចិត្តិយ ។ **ចប់អចេលកវគ្គទី ៥**

## សុរាបានវគ្គទី ៦

## [១០០] សុរាបាន សិក្ខាបទទី ៥១

សិក្ខាបទ ការផឹកសុរា

(បិ.៤.២០៩)

**សុរាមេរយបានេ បាចិត្តិយំ ។** ភិក្ខុផឹកសុរា និងមេរ័យត្រូវបាចិត្តិយ ។

## [១០១] អង្គុលិបតោទក សិក្ខាបទទី ៥២

សិក្ខាបទ ការចាក់ក្រឡេក

(បិ.៤.២១១.)

**អង្គុលិប្បតោទកេ បាចិត្តិយំ ។** ភិក្ខុចាក់ក្រឡេកប្រលែងគ្នា ដោយជន្លួញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

## [១០២] ហស្សធម្ម សិក្ខាបទទី ៥៣

សិក្ខាបទ ការលេងទឹក

(បិ.៤.២១៥.)

**ឧទកេ ហស្សធម្មេ បាចិត្តិយំ ។** ភិក្ខុលេងទឹកត្រូវអាបត្តិបាចិត្តិយ ។

## [១០៣] អនាទរិយ សិក្ខាបទទី ៥៤

សិក្ខាបទ ការមិនអើពើ

(បិ.៤.២១៨.)

**អនាទរិយេ បាចិត្តិយំ ។** ភិក្ខុមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

## [១០៤] ភឹសាបនៈ សិក្ខាបទទី ៥៥

សិក្ខាបទ ការបន្លាចឱ្យខ្លាច

(បិ.៤.២២១.)

**យោ បន ភិក្ខុ ភិក្ខុំ ភឹសាបេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ ធ្វើភិក្ខុផងគ្នាឱ្យខ្លាច ត្រូវអាបត្តិបាចិត្តិយ ។

## [១០៥] ជោតិសមាទហនៈ សិក្ខាបទទី ៥៦

សិក្ខាបទ ការអាំងភ្លើង

(បិ.៤.២២៦.)

**យោ បន ភិក្ខុ អគិលានោ វិសិព្វនាបេក្ខោ ជោតឹ សមាទហេយ្យ វា សមាទហាបេយ្យ វា អញ្ញត្រ តថារូបប្បច្ចយា, បាចិត្តិយំ ។**

ភិក្ខុណាមួយ មិនមានជំងឺមានបំណងនឹងអាំងភ្លើង ហើយបង្កាត់ខ្លួនឯងក្តី ប្រើគេឱ្យបង្កាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។

## [១០៦] ន្ហានៈ សិក្ខាបទទី ៥៧

សិក្ខាបទ ការងូតទឹក

(បិ.៤.២៣៤.)

**យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ន្ហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ "ទិយឌ្ឍោ មាសោ សេសោ គិម្ហាន"ន្តិ "វស្សានស្ស បឋមោ មាសោ" ឥច្ចេតេ, អឌ្ឍតេយ្យមាសា, ឧណ្ហសមយោ, បរិឡាហសមយោ, គិលានសមយោ, កម្មសមយោ, អទ្ធានគមនសមយោ, វាតវុដ្ឋិសមយោ, អយំ តត្ថ សមយោ ។**

ភិក្ខុណាមួយ មិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះ ដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា ២ ខែកន្លះ ហៅថា សម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជំងឺ សម័យធ្វើការងារ សម័យដើរផ្លូវឆ្ងាយ សម័យខ្យល់និងភ្លៀង នេះជាសម័យក្នុងសិក្ខាបទនោះ ។

## [១០៧] **ទុព្វណ្ណករណ សិក្ខាបទទី ៥៨**

សិក្ខាបទ ការធ្វើចីវរឱ្យខូចពណ៌

(បិ.៤.២៣៨.)

**នវំ បន ភិក្ខុនា ចីវរលាភេន តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ អាទាតព្វំ នីលំ វា កទ្ទមំ វា កាឡសាមំ វា ។ អនាទា ចេ ភិក្ខុ តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ នវំ ចីវរំ បរិភុញ្ជេយ្យ, បាចិត្តិយំ ។**

ភិក្ខុបានចីវរថ្មីមកហើយ គប្បីកាន់យកនូវវត្ថុសម្រាប់ ធ្វើឱ្យខូចពណ៌ ៣ យ៉ាង គឺពណ៌ខៀវក្តី ពណ៌ភក់ក្តី ពណ៌ខ្មៅជាំក្តី វត្ថុសម្រាប់ធ្វើឱ្យខូចពណ៌ណាមួយ បើភិក្ខុមិនកាន់យកនូវវត្ថុ សម្រាប់ធ្វើឱ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឱ្យខូចពណ៌ណាមួយទេ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ ។

## [១០៨] **វិកប្បនសិក្ខាបទទី ៥៩**

សិក្ខាបទ ការវិកប្បចីវរ

(បិ.៤.២៤២.)

**យោ បន ភិក្ខុ ភិក្ខុស្ស វា ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរស្ស វា សាមណេរិយា វា សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយបានវិកប្បចីវរដោយខ្លួនឯង ចំពោះភិក្ខុផងគ្នាក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ហើយប្រើប្រាស់ចីវរ ដែលមិនទាន់ឱ្យគេដកវិកប្បចេញសិន ត្រូវអាបត្តិបាចិត្តិយ ។

## [១០៩] ចីវរាបនិធាន សិក្ខាបទទី ៦០

សិក្ខាបទ ការលាក់ចីវរ

( បិ.៤.២៤៦.)

**យោ បន ភិក្ខុ ភិក្ខុស្ស បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ វា កាយពន្ធនំ វា អបនិធេយ្យ វា អបនិធាបេយ្យ វា អន្តមសោ ហស្សាបេក្ខោបិ, បាចិត្តិយំ ។**

ភិក្ខុណាមួយលាក់ទុកឯង ឬប្រើគេឱ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី របស់ភិក្ខុផងគ្នា ដោយហោចទៅ សូម្បីគ្រាន់តែមានបំណង នឹងសើចលេង ត្រូវអាបត្តិបាចិត្តិយ ។

## ចប់សុរាបានវគ្គទី ៦

## សប្បាណកវគ្គទី ៧

### [១១០] សញ្ចិច្ចបាណា សិក្ខាបទទី ៦១

សិក្ខាបទ ការក្លែងសម្លាប់សត្វ

(បិ.៤.២៥០.)

**យោ បន ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ ក្លែងផ្តាច់បង់សត្វចាកជីវិត ត្រូវអាបត្តិបាចិត្តិយ ។

### [១១១] សប្បាណក សិក្ខាបទទី ៦២

សិក្ខាបទ ការបរិភោគទឹកមានសត្វ

(បិ.៤.២៥២.)

**យោ បន ភិក្ខុ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយដឹងហើយ បរិភោគទឹកដែលមានសត្វមានជីវិត (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

### [១១២] ឧក្កោដន សិក្ខាបទទី ៦៣

សិក្ខាបទ ការសើរើអធិករណ៍

(បិ.៤.២៥៥.)

**យោ បន ភិក្ខុ ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងថា អធិករណ៍ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## [១១៣] ទុដ្ឋុល្ល សិក្ខាបទទី ៦៤

សិក្ខាបទ ការបិទបាំងអាបត្តិអាក្រក់

( បិ.៤.២៥៩.)

**យោ បន ភិក្ខុ ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយកាលដឹងហើយបិទបាំងទុក នូវអាបត្តិអាក្រក់របស់ភិក្ខុផងគ្នា (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

## [១១៤] ឩនវីសតិ សិក្ខាបទទី ៦៥

សិក្ខាបទ ការឱ្យឧបសម្បទាដល់កុលបុត្រ មានអាយុមិនគ្រប់ ២០ ឆ្នាំ

( បិ.៤.២៦៥.)

**យោ បន ភិក្ខុ ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេយ្យ, សោ ច បុគ្គលោ អនុបសម្បន្នោ តេ ច ភិក្ខូ គារយ្ហា ឥទំ តស្មឹ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងហើយឱ្យឧបសម្បទា ដល់បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំនោះ ក៏នៅជាអនុបសម្បន្នដដែល ចំណែកភិក្ខុទាំងឡាយនោះ អ្នកប្រាជ្ញគប្បីតិះដៀល នេះជាអាបត្តិបាចិត្តិយ ក្នុងរឿងនោះ ។

## [១១៥] ថេយ្យសត្ថ សិក្ខាបទទី ៦៦

សិក្ខាបទ ការធ្វើដំណើររួមនឹងឈ្មួញចោរ

( បិ.៤.២៦៩.)

**យោ បន ភិក្ខុ ជានំ ថេយ្យសត្ថេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ គាមន្តរម្បិ, បាចិត្តិយំ ។** ភិក្ខុណាមួយ កាលដឹងហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញជាចោរ ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។

## [១១៦] សំវិធាន សិក្ខាបទទី ៦៧

សិក្ខាបទ ការបបួលមាតុគ្រាមធ្វើដំណើរ តាមផ្លូវជាមួយគ្នា

( បិ.៤.២៧៣.)

**យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ គាមន្តរម្បិ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងហើយ បបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នាមួយអន្លើដោយមាតុគ្រាម ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។

## [១១៧] អរិដ្ឋ សិក្ខាបទទី ៦៨

សិក្ខាបទ អរិដ្ឋភិក្ខុមានទិដ្ឋិអាក្រក់

( បិ.៤.២៨១.)

**យោ បន ភិក្ខុ ឯវំ វទេយ្យ, "តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយា"តិ, សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ "មា អាយស្មា ឯវំ អវច, មា ភគវន្តំ អព្ភាចិក្ខិ, ន ហិ សាធុ ភគវតោ អព្ភក្ខានំ, ន ហិ ភគវា ឯវំ វទេយ្យ, អនេកបរិយាយេន អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា, អលញ្ច បន តេ បដិសេវតោ អន្តរាយាយា"តិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ ។ នោ ចេ បដិនិស្សជ្ជេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយពោលយ៉ាងនេះថា ធម៌ទាំងឡាយណាតែងធ្វើនូវសេចក្តីអន្តរាយ

ដែលព្រះដ៏មានព្រះភាគសម្តែងហើយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសម្តែងហើយដោយប្រការយ៉ាងនោះ ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុ លោកចូរកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ កាលពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយតែងធ្វើនូវសេចក្តីអន្តរាយ ដែលព្រះដ៏មានព្រះភាគ សម្តែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេពមែន ។ ឯភិក្ខុនោះ កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់មាំយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រ សមនុភាសនកម្មអស់វារៈបីដង ដើម្បីឱ្យលះទិដ្ឋិនោះចេញ ។ ភិក្ខុនោះកាលភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ហើយលះបង់ទិដ្ឋិនោះបាន ។ ការលះបង់បាននោះជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយ ។

## [១១៨] ឧក្ខិត្តសម្ភោគ សិក្ខាបទទី ៦៩

សិក្ខាបទ ការសេពគប់ជាមួយនឹងភិក្ខុដែលត្រូវសង្ឃលើកវត្ត

(បិ.៤.២៨៩.)

**យោ បន ភិក្ខុ ជានំ តថាវាទិនា ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជេយ្យ វា, សំវសេយ្យ វា, សហ វា សេយ្យំ កប្បេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលដឹងហើយ បរិភោគរួមក្តី នៅរួមក្តី សម្រេចឥរិយាបថដេក រួមក្តី ជាមួយនឹងភិក្ខុដែលមានប្រក្រតីពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះ ត្រូវអាបត្តិបាចិត្តិយ ។

## [១១៩] កណ្ឌក សិក្ខាបទទី ៧០

សិក្ខាបទ ការបញ្ចុះបញ្ចូលជាដើមនូវសមណុទ្ទេសឈ្មោះកណ្ឌកៈ

(បិ.៤.៣០០.)

**សមណុទ្ទេសោបិ ចេ ឯវំ វទេយ្យ "តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ, យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា, តេ បដិសេវតោ នាលំ អន្តរាយាយា"តិ, សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ "មា អាវុសោ សមណុទ្ទេស ឯវំ អវច, មា ភគវន្តំ អព្ភាចិក្ខិ, ន ហិ សាធុ ភគវតោ អព្ភក្ខានំ, ន ហិ ភគវា ឯវំ វទេយ្យ, អនេកបរិយាយេន អាវុសោ សមណុទ្ទេស អន្តរាយិកា ធម្មា វុត្តា ភគវតា, អលញ្ច បន តេ បដិសេវតោ អន្តរាយាយា" តិ ឯវញ្ច សោ សមណុទ្ទេសោ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ, សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ "អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតព្វោ, យម្បិ ចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទិ្វរត្តតិរត្តំ សហសេយ្យំ, សាបិ តេ នត្ថិ, ចរ បិរេ, វិនស្សា"តិ ។ យោ បន ភិក្ខុ ជានំ តថានាសិតំ សមណុទ្ទេសំ ឧបលាបេយ្យ វា, ឧបដ្ឋាបេយ្យ វា សម្ភុញ្ជេយ្យ វា សហ វា សេយ្យំ កប្បេយ្យ, បាចិត្តិយំ ។**

បើសមណុទ្ទេសពោលយ៉ាងនេះថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មាន ព្រះភាគសម្តែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ សម្តែងហើយថាជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើ

សេចក្ដីអន្ដរាយបុគ្គលអ្នកសេពទេ ។ សមណុទ្ទេសនោះភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស អ្នកឯងកុំនិយាយយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ សមណុទ្ទេស ធម៌ទាំងឡាយធ្វើសេចក្ដីអន្ដរាយដែលព្រះដ៏មានព្រះភាគសម្ដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះអាចធ្វើនូវសេចក្ដីអន្ដរាយដល់អ្នកសេព (មែន) ។ សមណុទ្ទេសនោះកាលដែលភិក្ខុទាំងឡាយ ពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់ដដែល សមណុទ្ទេសនោះភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស កាលមានថ្ងៃនេះជាដើម អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះថាជាសាស្ដារបស់អ្នកឡើយ សាមណេរទាំងឡាយដទៃតែងបានកិរិយាដេកនៅរួមនោះ មិនមានដល់អ្នកទេ នែមនុស្សក្រៅការ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ ។ ភិក្ខុណាមួយដឹងថា សមណុទ្ទេសដែលសង្ឃឱ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលក្ដី ឱ្យបម្រើក្ដី បរិភោគរួមក្ដី សម្រេចឥរិយាបថដេករួមក្ដី ភិក្ខុនោះត្រូវអាបត្ដិបាចិត្ដិយ ។

**ចប់សប្បាណកវគ្គទី ៧**

# សហធម្មិកវគ្គទី ៨

## [១២០] សហធម្មិក សិក្ខាបទទី ៧១

សិក្ខាបទ ការពោលពាក្យប្រកបដោយធម៌

(បិ.៤.៣០៧)

**យោ បន ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯវំ វទេយ្យ "ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ, យាវ នញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមី"តិ, បាចិត្តិយំ ។ សិក្ខមានេន ភិក្ខវេ ភិក្ខុនា អញ្ញាតព្វំ បរិបុច្ឆិតព្វំ បរិបញ្ហិតព្វំ, អយំ តត្ថ សាមីចិ ។**

ភិក្ខុណាមួយកាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ ហើយពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្លាស ដែលទ្រទ្រង់វិន័យដរាបណា ខ្ញុំនឹងមិនសិក្សាសិក្ខាបទនេះដរាបនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសិក្សាគួរដឹងច្បាស់ គួរសាកសួរ គួរពិចារណា ។ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

## [១២១] វិលេខន សិក្ខាបទទី ៧២

សិក្ខាបទ ការពោលបង្អាប់សិក្ខាបទ

(បិ.៤.៣១២.)

**យោ បន ភិក្ខុ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេយ្យ "កិំ បនិមេហិ ខុទ្ទានុខុទ្ទកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ, យាវទេវ កុក្កុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តី"តិ, សិក្ខាបទវិវណ្ណនកេ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលបើភិក្ខុសម្តែងឡើងនូវបាតិមោក្ខ ហើយពោលយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទតូច ៗ ទាំងនេះដែលភិក្ខុណាមួយសម្តែងឡើង ហើយសិក្ខាបទទាំងឡាយនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីក្តៅក្រហាយចិត្ត

ដើម្បីសេចក្តីលំបាកចិត្ត ដើម្បីសេចក្តីរសេមរសាមចិត្តប៉ុណ្ណោះឯង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះពោលបង្អាប់សិក្ខាបទ ។

## [១២២] មោហន សិក្ខាបទទី ៧៣

សិក្ខាបទ ការក្លែងធ្វើជាវង្វេង

(បិ.៤.៣១៦.)

**យោ បន ភិក្ខុ អន្វឌ្ឍមាសំ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេយ្យ "ឥទានេវ ខោ អហំ ជានាមិ, អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតី"តិ ។ តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានេយ្យុំ និសិន្នបុព្វំ ឥមិនា ភិក្ខុនា ទ្វិត្តិក្ខត្តុំ បាតិមោក្ខេ ឧទ្ទិស្សមានេ, កោ បន វាទោ ភិយ្យោតិ, ន ច តស្ស ភិក្ខុនោ អញ្ញាណកេន មុត្តិ អត្ថិ យញ្ច តត្ថ អាបត្តឹ អាបន្នោ តញ្ច យថាធម្មោ ការេតព្វោ, ឧត្តរិញ្ចស្ស មោហោ អារោបេតព្វោ "តស្ស តេ អាវុសោ អលាភា, តស្ស តេ ទុល្លទ្ធំ, យំ ត្វំ បាតិមោក្ខេ ឧទ្ទិស្សមានេ ន សាធុកំ អដ្ឋិកត្វា មនសិករោសី"តិ ឥទំ តស្មឹ មោហនកេ បាចិត្តិយំ ។**

ភិក្ខុណាមួយ កាលភិក្ខុកំពុងសម្តែងបាតិមោក្ខរាល់កន្លះខែ ហើយពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ឮថាធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេសរាល់កន្លះខែ ។ បើភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុនោះថា ភិក្ខុនេះធ្លាប់អង្គុយស្តាប់បាតិមោក្ខ ដែលភិក្ខុសម្តែងអស់វារៈពីរបីដងហើយ នឹងពោលទៅថ្វីទៀតដល់ការស្តាប់ច្រើនដង សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹងមិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណា ក្នុងរឿងអនាចារនោះ សង្ឃគប្បីញ៉ាំងភិក្ខុនោះឱ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ ម្យ៉ាងទៀត គប្បីលើកមោហារោបនកម្មដល់ភិក្ខុនោះថែមទៀតថា ម្នាលអាវុសោ (ការនេះ) មិនជាលាភរបស់អ្នកឯងទេ អ្នកឯង

បាននូវរបស់អាក្រក់ ដោយហេតុថា កាលភិក្ខុកំពុងសម្តែងបាតិមោក្ខ អ្នកមិនបានធ្វើទុកក្នុងចិត្តឱ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ ។ នេះជាអាបត្តិបាចិត្តិយ ព្រោះក្លែងធ្វើវង្វេងនោះ (ធ្វើពើ) ។

## [១២៣] បហារ សិក្ខាបទទី ៧៤

សិក្ខាបទ ការវាយប្រហារ

(បិ.៤.៣២២.)

**យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ បហារំ ទទេយ្យ បាចិត្តិយំ ។**
ភិក្ខុណាមួយ ក្រោធខឹងហើយឱ្យប្រហារដល់ភិក្ខុផងគ្នា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [១២៤] តលសត្តិក សិក្ខាបទទី ៧៥

សិក្ខាបទ ការងាលំពែង គឺ បាតដៃ

(បិ.៤.៣២៥.)

**យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរេយ្យ បាចិត្តិយំ ។**
ភិក្ខុណាមួយក្រោធខឹង ហើយងាឡើងនូវលំពែងគឺបាតដៃសំដៅភិក្ខុផងគ្នា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [១២៥] អមូលក សិក្ខាបទទី ៧៦

សិក្ខាបទ ការចោទដោយអាបត្តិមិនមានមូល

(បិ.៤.៣២៨.)

**យោ បន ភិក្ខុ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេយ្យ បាចិត្តិយំ ។**
ភិក្ខុណាមួយ ចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។

## [១២៦] សញ្ចិច្ច សិក្ខាបទទី ៧៧

សិក្ខាបទ ការក្លែងបង្កហេតុឱ្យកើតសេចក្តីរង្កៀសសង្ស័យ

(បិ.៤.៣៣១.)

**យោ បន ភិក្ខុ ភិក្ខុស្ស សញ្ចិច្ច កុក្កុច្ចំ ឧបទហេយ្យ "ឥតិស្ស មុហុត្តម្បិ អផាសុ ភវិស្សតីតិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ បាចិត្តិយំ ។**

ភិក្ខុណាមួយក្លែងបង្ក ហេតុឱ្យមានសេចក្តីរង្កៀសសង្ស័យដល់ភិក្ខុផង គ្នាដោយគិតថា (សេចក្តីរង្កៀសសង្ស័យនេះ) កើតឡើង ការមិនសប្បាយចិត្ត នឹងមានដល់ភិក្ខុនោះមួយ រំពេចមិនខាន ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើសេចក្តីរង្កៀសសង្ស័យ នោះឯងជាហេតុពិត មិនមែនហេតុដទៃឡើយ ។

## [១២៧] ឧបស្សុតិក សិក្ខាបទទី ៧៨

សិក្ខាបទ ការអែបស្តាប់ (ពាក្យជាហេតុទាស់ទែងគ្នា)

(បិ.៤.៣៣៨.)

**យោ បន ភិក្ខុ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋេយ្យ "យំ ឥមេ ភណិស្សន្តិ តំ សោស្សាមីតិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ បាចិត្តិយំ ។**

ភិក្ខុណាមួយកាលបើភិក្ខុទាំងឡាយ បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ទៅឈរអែបស្តាប់ដោយគិតថា ភិក្ខុទាំងនេះនឹងពោលពាក្យណា អញនឹងស្តាប់ពាក្យនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើកិរិយាឈរអែបស្តាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ ។

## [១២៨] **កម្មបដិពាហន សិក្ខាបទទី ៧៩**

សិក្ខាបទ ការជំទាស់កម្ម

(បិ.៤.៣៣៩.)

**យោ បន ភិក្ខុ ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយ ឱ្យឆន្ទៈដើម្បីកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយពោលតិះដៀលជាខាងក្រោយ ត្រូវអាបត្តិបាចិត្តិយ ។

## [១២៩] **ឆន្ទំអទត្វាគមន សិក្ខាបទទី ៨០**

សិក្ខាបទ ការមិនឱ្យឆន្ទៈ

(បិ.៤.៣៤២.)

**យោ បន ភិក្ខុ សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយកាលពាក្យវិនិច្ឆ័យកំពុងប្រព្រឹត្តទៅក្នុងសង្ឃ មិនឱ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

## [១៣០] **ឧទព្វ សិក្ខាបទទី ៨១**

សិក្ខាបទ ការឱ្យចីវរដល់ព្រះទព្វមល្លបុត្រ

(បិ.៤.៣៤៦.)

**យោ បន ភិក្ខុ សមគ្គេន សង្ឃេន ចីវរំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ យថាសន្ថុតំ ភិក្ខូ សង្ឃិកំ លាភំ បរិណាមេន្តីតិ បាចិត្តិយំ ។**

ភិក្ខុណាមួយ (កាលបើ) សង្ឃព្រមព្រៀងគ្នាឱ្យចីវរ (ដល់ភិក្ខុ) ហើយក៏ដល់នូវធម៌គឺកិរិយាតិះដៀលជាខាងក្រោយវិញថា ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃ តាមសេចក្តីគាប់ចិត្ត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## [១៣១] **បរិណាមន សិក្ខាបទទី ៨២**

សិក្ខាបទ ការបង្អោនលាភសង្ឃ

(បិ.៤.៣៩១.)

**យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេយ្យ បាចិត្តិយំ ។**

ភិក្ខុណាមួយដឹងថា លាភរបស់សង្ឃគេបង្អោនទៅ (ដើម្បីសង្ឃហើយ) ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

## **ចប់សហធម្មិកវគ្គទី ៨**

## រតនវគ្គទី ៩

## [១៣២] អន្តេបុរ សិក្ខាបទទី ៨៣

សិក្ខាបទ ការចូលកាន់ព្រះរាជដ្ឋាន

(បិ.៤.៣៦២.)

**យោ បន ភិក្ខុ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស អនិក្ខន្តរាជកេ អនិគ្គតរតនកេ បុព្វេ អប្បដិសំវិទិតោ ឥន្ទខីលំ អតិក្កាមេយ្យ, បាចិត្តិយំ ។**

ភិក្ខុណាមួយ (បើ) ស្តេចជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ មិនទាន់ជ្រាបជាមុន ឈានកន្លងធរណីទ្វារចូលទៅក្នុងក្រឡាព្រះបន្ទំ ដែលស្តេចមិនទាន់យាងចេញ ស្រីកែវក៏មិនទាន់ចេញ ត្រូវអាបត្តិបាចិត្តិយ ។

## [១៣៣] រតន សិក្ខាបទទី ៨៤

សិក្ខាបទ ការរើសរតនៈ

(បិ.៤.៣៧០)

**យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា អញ្ញត្រ អជ្ឈារាមា វា អជ្ឈាវសថា វា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា បាចិត្តិយំ ។ រតនំ វា បន ភិក្ខុនា រតនសម្មតំ វា អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបិតព្វំ "យស្ស ភវិស្សតិ, សោ ហរិស្សតី"តិ, ។ អយំ តត្ថ សាមីចិ ។**

ភិក្ខុណាមួយរើសឯងក្តី ឱ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែខាងក្នុងវត្ត ឬខាងក្នុងទីស្នាក់ ។ ម៉្យាងទៀត ភិក្ខុគប្បីរើសឯង ឬឱ្យគេរើស នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងអារាមក្តី ខាងក្នុងទីស្នាក់ក្តី ហើយទុកដាក់ដោយគិតថា រតនៈរបស់ជនណា ជននោះនឹងនាំយកទៅ ។ នេះជាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

## [១៣៤] វិកាលគាមប្បវេសន សិក្ខាបទទី ៨៥

សិក្ខាបទ ការចូលស្រុកក្នុងវេលាវិកាល

(បិ. ៤. ៣៧៨.)

**យោ បន ភិក្ខុ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសេយ្យ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយា, បាចិត្តិយំ ។**

ភិក្ខុណាមួយមិនបានលាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ ។

## [១៣៥] សូចិឃរ សិក្ខាបទទី ៨៦

សិក្ខាបទ ការធ្វើបំពង់ម្ជុល

(បិ. ៤. ៣៨២.)

**យោ បន ភិក្ខុ អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិឃរំ ការាបេយ្យ ភេទនកំ បាចិត្តិយំ ។**

ភិក្ខុណាមួយឱ្យគេធ្វើបំពង់ម្ជុលជាវិការនៃឆ្អឹងក្តី ជាវិការនៃភ្លុកក្តី ជាវិការនៃស្នែងក្តី ត្រូវភេទនកបាចិត្តិយ ។

## [១៣៦] មញ្ចបីឋ សិក្ខាបទទី ៨៧

សិក្ខាបទ ការធ្វើគ្រែតាំងហួសប្រមាណ (៨ធ្នាប់ព្រះសុគត)

(បិ. ៤. ៣៨៤.)

**នវំ បន ភិក្ខុនា មញ្ចំ វា បីឋំ វា ការយមានេន អដ្ឋង្គុលបាទកំ ការេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិយា ។ តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយំ ។**

ភិក្ខុឱ្យគេធ្វើគ្រែក្ដី តាំងក្ដីដ៏ថ្មី ត្រូវឱ្យធ្វើឱ្យមានជើង ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត វាស់ពីត្រឹមមេគ្រែខាងក្រោមចុះទៅ (បើធ្វើ) ឱ្យកន្លងហួសពីនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

## [១៣៧] តូលោនទ្ធ សិក្ខាបទទី ៨៨

សិក្ខាបទ ការធ្វើគ្រែតាំងញាត់ដោយសំឡី

(បិ.៤.៣៨៩.)

**យោ បន ភិក្ខុ មញ្ចំ វា បីឋំ វា តូលោនទ្ធំ ការាបេយ្យ ឧទ្ទាលនកំ បាចិត្តិយំ ។**

ភិក្ខុណាមួយឱ្យគេធ្វើគ្រែក្ដី តាំងក្ដី ញាត់ដោយសំឡី ត្រូវឧទ្ទាលនកបាចិត្តិយ ។

## [១៣៨] និសីទន សិក្ខាបទទី ៨៩

សិក្ខាបទ ការធ្វើសំពត់ទ្រាប់អង្គុយហួសប្រមាណ

(បិ.៤.៣៩៤.)

**និសីទនំ បន ភិក្ខុនា ការយមានេន បមាណិកំ ការេតព្វំ, តត្រិទំ បមាណំ, ទីឃសោ ទ្វេ វិទត្ថិយោ សុគតវិទត្ថិយា , តិរិយំ ទិយឌ្ឍំ, ទសាវិទត្ថិ ។ តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយំ ។**

ភិក្ខុនឹងឱ្យគេធ្វើសំពត់និសីទនៈត្រូវឱ្យគេធ្វើឱ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់និសីទនៈនោះយ៉ាងនេះ គឺបណ្ដោយ ២ ចំអាម ទទឹង ១ ចំអាមកន្លះ នឹងជាយ ១ ចំអាម ដោយចំអាមព្រះសុគត ។ (បើភិក្ខុធ្វើ)ឱ្យកន្លងហួសពីនោះទៅត្រូវឆេទនកបាចិត្តិយ ។

## [១៣៩] កណ្ឌុប្បដិច្ឆាទិ សិក្ខាបទទី ៩០

សិក្ខាបទ ការធ្វើសំពត់គ្របកមហួសប្រមាណ

(បិ.៤.៣៩៧.)

**កណ្ឌុប្បដិច្ឆាទឹ បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា, តត្រិទំ បមាណំ, ទីឃសោ ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា, តិរិយំ ទ្វេ វិទត្ថិយោ ។ តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយំ ។**

ភិក្ខុធ្វើសំពត់ សម្រាប់គ្របកមត្រូវឱ្យគេធ្វើឱ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់សម្រាប់គ្របកមនោះ យ៉ាងនេះ គឺបណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឱ្យកន្លងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

## [១៤០] វស្សិកសាដិក សិក្ខាបទទី ៩១

សិក្ខាបទ ការធ្វើសំពត់ងូតទឹកភ្លៀងហួសប្រមាណ

(បិ.៤.៤០០.)

**វស្សិកសាដិកំ បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា, តត្រិទំ បមាណំ, ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា, តិរិយំ អឌ្ឍតេយ្យា ។ តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយំ ។**

ភិក្ខុឱ្យគេធ្វើសំពត់វស្សិកសាដក ត្រូវឱ្យគេធ្វើត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់វស្សិកសាដកនោះ យ៉ាងនេះគឺ បណ្តោយ ៦ ចំអាម ទទឹង ២ ចំអាមកន្លះ ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឱ្យកន្លងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

## [១៤១] សុគតចីវរ សិក្ខាបទទី ៩២

សិក្ខាបទ ការធ្វើចីវរប៉ុនសុគតចីវរ

(បិ.៤.៤០៣.)

**យោ បន ភិក្ខុ សុគតចីវរប្បមាណំ ចីវរំ ការាបេយ្យ, អតិរេកំ វា, ឆេទនកំ បាចិត្តិយំ ។ តត្រិទំ សុគតស្ស សុគតចីវរប្បមាណំ ទីឃសោ នវ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ឥទំ សុគតស្ស សុគតចីវរប្បមាណំ ។**

ភិក្ខុណាមួយ ឱ្យគេធ្វើចីវរប៉ុនចីវរព្រះសុគត ឬធំជាង ត្រូវឆេទនកបាចិត្តិយ ។ ឯប្រមាណសុគតចីវររបស់ព្រះសុគតនោះ យ៉ាងនេះគឺ បណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាមដោយចំអាមព្រះសុគត ។ នេះជាប្រមាណសុគតចីវររបស់ព្រះសុគត ។

**ចប់រតនវគ្គទី ៩**

**ចប់បាចិត្តិយកណ្ឌ**

# បាដិទេសនីយកណ្ឌ

## [១៤២] អញ្ញាតិកាយ សិក្ខាបទទី ១

សិក្ខាបទ ការទទួលខាទនីយ ឬភោជនីយអំពីដៃភិក្ខុនី មិនមែនញាតិក្នុងចន្លោះផ្ទះ

(បិ.៤.៤០៨.)

**យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមី"តិ ។**

ភិក្ខុណាមួយទទួលយក ខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះហើយ ទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសម្តែងអាបត្តិបាដិទេសនីយៈថា ម្នាលអាវុសោខ្ញុំត្រូវអាបត្តិបាដិទេសនីយៈ ដែលព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលហើយ មិនជាទីសប្បាយ ឥឡូវខ្ញុំសូមសម្តែងអាបត្តិនោះចេញ ។

## [១៤៣] នប្បដិភាសេយ្យ សិក្ខាបទទី ២

សិក្ខាបទ ការមិនបានពោលបណ្តេញភិក្ខុនី ដែលឈរបង្គាប់គេ

(បិ.៤.៤១៣.)

**ភិក្ខូ បនេវ កុលេសុ និមន្តិតា ភុញ្ជន្តិ, តត្រ ចេ ភិក្ខុនី វោសាសមានរូបា ឋិតា ហោតិ"ឥធ សូបំ ទេថ, ឥធ ឱទនំ ទេថា"តិ ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសាទេតព្វា "អបសក្ក តាវ ភគិនិ, យាវ ភិក្ខូ ភុញ្ជន្តី"តិ ។ ឯកស្សបិ ចេ ភិក្ខុនោ នប្បដិភាសេយ្យ តំ ភិក្ខុនី អបសាទេតុំ អបសក្ក តាវ ភគិនិ, យាវ ភិក្ខូ ភុញ្ជន្តី"តិ, បដិទេសេតព្វំ តេហិ ភិក្ខូហិ "គារយ្ហំ អាវុសោ ធម្មំ អាបជ្ជិម្ហា អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមា"តិ ។**

ភិក្ខុទាំងឡាយដែលជនបាននិមន្តហើយ ឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ ។ បើមានភិក្ខុនីមកឈរបង្គាប់គេជិតទីនោះថា អ្នកទាំងឡាយចូរប្រគេនសម្លមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ ។ ភិក្ខុទាំងនោះ ត្រូវបណ្តេញភិក្ខុនីនោះថា នែនាងៗ ចូរថយចេញទៅសិនទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់ ។ ភិក្ខុសូម្បី ១ រូប បើមិនបានពោលបណ្តេញភិក្ខុនីនោះដោយពាក្យថា នែនាងៗ ចូរថយចេញទៅ ទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់ ដូច្នេះសិនទេ ភិក្ខុទាំងនោះត្រូវសម្តែងដោយពាក្យថា ម្នាលអាវុសោ យើងត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយ ឥឡូវខ្ញុំសូមសម្តែងអាបត្តិនោះចេញ ។

## [១៩៤] សេក្ខសម្មតិ សិក្ខាបទទី ៣

សិក្ខាបទ ការសន្មតិត្រកូលដែលជាព្រះសេក្ខ

(បិ.៤.៤២១.)

**យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានិ, យោ បន ភិក្ខុ តថារូបេសុ សេក្ខសម្មតេសុ កុលេសុ បុព្វេ អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមី"តិ ។**

ពួកត្រកូលណាមួយ ដែលសង្ឃបានសន្មតថា ជាសេក្ខត្រកូលហើយ ភិក្ខុណាមួយ ឥតមានគេនិមន្តក្នុងកាលមុន ហើយឥតទាំងមានជំងឺ បានទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីត្រកូលដែលសង្ឃបានឱ្យសេក្ខសម្មតិបែបនោះហើយ (យកមក) ទំពាស៊ី ឬបរិភោគភិក្ខុនោះត្រូវសម្តែងថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទី

សប្បាយ ដែលព្រះដ៏មានព្រះភាគ ទ្រង់តិះដៀល ខ្ញុំសូមសម្ដែងអាបត្តិនោះចេញ ។

## [១៩៥] អរញ្ញកសេនាសន សិក្ខាបទទី ៤

សិក្ខាបទ ការនៅក្នុងសេនាសនៈព្រៃ

(បិ. ៤. ៤២៨.)

**យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ, យោ បន ភិក្ខុ តថារូបេសុ សេនាសនេសុ វិហរន្តោ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា, ភោជនីយំ វា, អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទេយ្យ វា ភុញ្ជេយ្យ វា, បដិទេសេតព្វំ តេន ភិក្ខុនា "គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។**

ទីសេនាសនៈណាទាំងឡាយណាមួយ ដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាទីប្រកបដោយរង្កៀស ប្រកបដោយភ័យចំពោះមុខ ភិក្ខុណាមួយ ឥតមានជំងឺនៅក្នុងទីសេនាសនៈទាំងឡាយមានសភាពដូច្នោះ បានទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដែលគេមិនបានឱ្យដំណឹងជាមុន ដោយដៃរបស់ខ្លួនក្នុងអារាម (ហើយយកមក) ទំពាស៊ី ឬ បរិភោគ ភិក្ខុនោះត្រូវសម្ដែងអាបត្តិថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគ ទ្រង់តិះដៀល ខ្ញុំសូមសម្ដែងនូវអាបត្តិនោះចេញ ។

## ចប់បាដិទេសនីយកណ្ឌ

# សេខិយវគ្គកណ្ឌ

## [១៤៦] បឋមបរិមណ្ឌល សិក្ខាបទទី ១

សិក្ខាបទ ការស្លៀកស្បង់ឱ្យជាបរិមណ្ឌល

(បិ.៤.៤៣៥.៤៣៦.)

**បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងស្លៀក (ស្បង់) ឱ្យជាបរិមណ្ឌល ។

## [១៤៧] ទុតិយបរិមណ្ឌល សិក្ខាបទទី ២

សិក្ខាបទ ការដណ្តប់ចីវរឱ្យជាបរិមណ្ឌល

**បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងដណ្តប់ (ចីវរ) ឱ្យជាបរិមណ្ឌល ។

## [១៤៨] បឋមសុប្បដិច្ឆន្ន សិក្ខាបទទី ៣

សិក្ខាបទ ការបិទបាំងកាយឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៣៦.៤៣៧.)

**សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងបិទបាំងឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៤៩] ទុតិយសុប្បដិច្ឆន្ន សិក្ខាបទទី ៤

សិក្ខាបទ ការបិទបាំងកាយឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ

**សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងបិទបាំងឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៥០] **បឋមសុសំវុតំ សិក្ខាបទទី ៥**

សិក្ខាបទ ការសង្រួមឱ្យល្អដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៣៨.)

**សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសង្រួមឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៥១] **ទុតិយសុសំវុតំ សិក្ខាបទទី ៦**

សិក្ខាបទ ការសង្រួមឱ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ

**សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសង្រួមឱ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៥២] **បឋមឱក្ខិត្តចក្ខុ សិក្ខាបទទី ៧**

សិក្ខាបទ មានភ្នែកសម្លឹងចុះដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៣៩.៤៤០.)

**ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថាអញនឹងមានភ្នែកសម្លឹងចុះដើរទៅក្នុងចន្លោះផ្ទះ ។

## [១៥៣] **ទុតិយឱក្ខិត្តចក្ខុ សិក្ខាបទទី ៨**

សិក្ខាបទ មានភ្នែកសម្លឹងចុះអង្គុយនៅក្នុងចន្លោះផ្ទះ

**ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមានភ្នែកសម្លឹងចុះ អង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៥៤] បឋមឧក្ខិត្តក សិក្ខាបទទី ៩

សិក្ខាបទ ការមិនសើយចីវរដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤១.)

**ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៥៥] ទុតិយឧក្ខិត្តក សិក្ខាបទទី ១០

សិក្ខាបទ ការមិនសើយចីវរអង្គុយនៅក្នុងចន្លោះផ្ទះ

**ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសើយចីវរ អង្គុយនៅក្នុងចន្លោះផ្ទះ ។

## ចប់បរិមណ្ឌលវគ្គទី ១

## [១៥៦] បឋមឧជ្ជគ្ឃិក សិក្ខាបទទី ១១

សិក្ខាបទ ការមិនសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤២.)

**ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៥៧] ទុតិយឧជ្ជគ្ឃិក សិក្ខាបទទី ១២

សិក្ខាបទ ការមិនសើចខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះ

**ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៥៨] **បឋមអប្បសទ្ទ សិក្ខាបទទី ១៣**

សិក្ខាបទ មានសំឡេងតិចដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៣.៤៤៤.)

**អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងនិយាយសំដីតិច ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៥៩] **ទុតិយអប្បសទ្ទ សិក្ខាបទទី ១៤**

សិក្ខាបទ មានសំឡេងតិចអង្គុយនៅក្នុងចន្លោះផ្ទះ

**អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងនិយាយសំដីតិច អង្គុយក្នុងចន្លោះផ្ទះ ។

## [១៦០] **បឋមកាយប្បចាលក សិក្ខាបទទី ១៥**

សិក្ខាបទ ការមិនគ្រវែងកាយដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៤/៤៤៥.)

**ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រវែងកាយ ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៦១] **ទុតិយកាយប្បចាលក សិក្ខាបទទី ១៦**

សិក្ខាបទ ការមិនគ្រវែងកាយអង្គុយនៅក្នុងចន្លោះផ្ទះ

**ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រវែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៦២] **បឋមពាហុប្បចាលក សិក្ខាបទទី ១៧**

សិក្ខាបទ ការមិនបង់បោយដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៥.៤៤៦.)

**ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបង់បោយ ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៦៣] **ទុតិយពាហុប្បចាលក សិក្ខាបទទី ១៨**

សិក្ខាបទ ការមិនឆ្កាវដៃអង្គុយនៅក្នុងចន្លោះផ្ទះ

**ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆ្កាវដៃអង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៦៤] **បឋមសីសប្បចាលក សិក្ខាបទទី ១៩**

សិក្ខាបទ ការមិនគ្រវែងក្បាលដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៦.៤៤៧.)

**ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រវែងក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៦៥] **ទុតិយសីសប្បចាលក សិក្ខាបទទី ២០**

សិក្ខាបទ ការមិនគ្រវែងក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ

**ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រវែងក្បាលអង្គុយនៅក្នុងចន្លោផ្ទះ។

**ចប់ឧជ្ជគ្ឃិកវគ្គទី ២**

## [១៦៦] បឋមខម្ភកត សិក្ខាបទទី ២១

សិក្ខាបទ ការមិនស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៨.)

**ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹង(មិនយកដៃ) ស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ ។

## [១៦៧] ទុតិយខម្ភកត សិក្ខាបទទី ២២

សិក្ខាបទ ការមិនស្ទឹមចង្កេះអង្គុយនៅក្នុងចន្លោះផ្ទះ

**ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹង (មិនយកដៃ) ស្ទឹមចង្កេះអង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៦៨] បឋមឱគុណ្ឋិត សិក្ខាបទទី ២៣

សិក្ខាបទ ការមិនទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៤៩.)

**ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

## [១៦៩] ទុតិយឱគុណ្ឋិត សិក្ខាបទទី ២៤

សិក្ខាបទ ការមិនទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ

**ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

## [១៧០] ឧក្កុដិក សិក្ខាបទទី ២៥

សិក្ខាបទ ការមិនចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ

(បិ.៤.៤៨០.)

**ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនចំអើតជើង ហើយដើរទៅក្នុងចន្លោះផ្ទះ ។

## [១៧១] បល្លត្ថិក សិក្ខាបទទី ២៦

សិក្ខាបទ ការមិនអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ

(បិ.៤.៤៨១.)

**ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនអង្គុយ ត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ។

## ឆព្វីសតិ សារុប្បា

## ចប់សរុប ២៦

## [១៧២] សក្កច្ចបដិគ្គហណ សិក្ខាបទទី ២៧

សិក្ខាបទ ការទទួលអាហារបិណ្ឌបាតដោយគោរព

(បិ.៤.៤៨១.)

**សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងទទួលអាហារបិណ្ឌបាតដោយគោរព ។

## [១៧៣] **បត្តសញ្ញីបដិគ្គហណ សិក្ខាបទទី ២៨**

សិក្ខាបទ ការសម្គាល់ក្នុងបាត្រហើយទទួលបិណ្ឌបាត្រ

(បិ.៤.៤៩២.)

**បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសម្គាល់ក្នុងបាត្រ ហើយទទួលបិណ្ឌបាត ។

## [១៧៤] **សមសូបកបដិគ្គហណ សិក្ខាបទទី ២៩**

សិក្ខាបទ ការទទួលបិណ្ឌបាត្រឱ្យល្មមគ្នានឹងសម្ល

(បិ.៤.៤៩៣.)

**សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងទទួលបិណ្ឌបាត ឱ្យល្មមគ្នានឹងសម្ល ។

## [១៧៥] **សមតិត្តិកបដិគ្គហណ សិក្ខាបទទី ៣០**

សិក្ខាបទ ការទទួលបិណ្ឌបាត្រឱ្យស្មើនឹងកណ្ដាប់មាត់បាត្រ

(បិ.៤.៤៩៣.)

**សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងទទួលបិណ្ឌបាត ឱ្យស្មើត្រឹមកណ្ដាប់មាត់បាត្រ ។

## **ចប់ខម្ពកវគ្គទី ៣**

## [១៧៦] សក្កច្ចបិណ្ឌបាតគ្គហណ សិក្ខាបទទី ៣១

សិក្ខាបទ ការឆាន់បិណ្ឌបាតដោយគោរព

(បិ.៤.៤៥៥.)

**សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងឆាន់បិណ្ឌបាត ដោយគោរព ។

## [១៧៧] បត្តសញ្ញីបិណ្ឌបាតគ្គហណ សិក្ខាបទទី ៣២

សិក្ខាបទ ការសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត្រ

(បិ.៤.៤៥៥.)

**បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសម្គាល់តែក្នុងបាត្រ ឆាន់បិណ្ឌបាត ។

## [១៧៨] សបទានបិណ្ឌបាតគ្គហណ សិក្ខាបទទី ៣៣

សិក្ខាបទ ការឆាន់បិណ្ឌបាត្រវាចឱ្យស្មើ

(បិ.៤.៤៥៦.)

**សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងឆាន់ បិណ្ឌបាតវាចឱ្យស្មើ ។

## [១៧៩] សមសូបកបិណ្ឌបាតគ្គហណ សិក្ខាបទទី ៣៤

សិក្ខាបទ ការឆាន់បិណ្ឌបាត្រឱ្យល្មមគ្នានឹងសម្ល

(បិ.៤.៤៥៦.)

**សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងឆាន់ បិណ្ឌបាតឱ្យល្មមគ្នានឹងសម្ល ។

## [១៨០] នថូបិកតោមទ្ទិនភុញ្ជន សិក្ខាបទទី ៣៥

សិក្ខាបទ ការមិនច្រមត្រង់កំពូលបាយហើយឆាន់

(បិ.៤.៤៩៧.)

**ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនបានច្រមត្រង់កំពូលបាយហើយឆាន់ បិណ្ឌបាត ។

## [១៨១] នសូបព្យញ្ជនោទនបដិច្ឆាទន សិក្ខាបទទី ៣៦

សិក្ខាបទ ការមិនកកាយបាយលុបសម្លឬម្ហូប

(បិ.៤.៤៩៨.)

**ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេស្សាមិ ភិយ្យោកម្យតំ ឧបាទាយាតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនកកាយបាយលុបសម្ល ឬម្ហូបព្រោះ អាស្រ័យសេចក្ដីល្មោភច្រើន ។

## [១៨២] នសូបោទនវិញ្ញត្តិ សិក្ខាបទទី ៣៧

សិក្ខាបទ ការមិនត្រូវសូមសម្លឬបាយ

(បិ.៤.៤៦១.)

**ន សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញឥតមានជំងឺនឹងមិនសូមសម្ល ឬបាយ ដើម្បី ប្រយោជន៍ខ្លួនហើយឆាន់ ។

## [១៨៣] នឧជ្ឈានសញ្ញីបត្តោលោកន សិក្ខាបទទី ៣៨

សិក្ខាបទ ការមិនសម្លឹងមើលបាត្រពួកភិក្ខុដទៃ ដោយប្រុងលើកទោស
(បិ.៤.៤៦២.)

**ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនប្រុងលើកទោស ហើយសម្លឹងមើលបាត្រពួកភិក្ខុដទៃ ។

## [១៨៤] នាតិមហន្តកពឡករណ សិក្ខាបទទី ៣៩

សិក្ខាបទ ការមិនធ្វើពុំនូតបាយឱ្យធំពេក
(បិ.៤.៤៦២.)

**នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនធ្វើពំនូតបាយឱ្យធំពេក ។

## [១៨៥] បរិមណ្ឌលអាលោបករណ សិក្ខាបទទី ៤០

សិក្ខាបទ ការធ្វើពុំនូតបាយឱ្យជាបរិមណ្ឌល
(បិ.៤.៤៦៣.)

**បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងធ្វើពំនូតបាយឱ្យជាបរិមណ្ឌល គឺឱ្យមូល ។

**ចប់សក្កច្ចវគ្គទី ៤**

## [១៨៦] **នអនាហដទ្វារវិវរណ សិក្ខាបទទី ៤១**

សិក្ខាបទ ការមិនហាមាត់ចាំពំនូតបាយ

(ឋិ.៤.៤៦៤.)

**ន អនាហដេ កពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា កាលពំនូតបាយ មិនទាន់មកដល់ អញនឹងបើកទ្វារមាត់ចាំ ។

## [១៨៧] **នសព្វហត្ថបក្ខិបន សិក្ខាបទទី ៤២**

សិក្ខាបទ ការឆាន់បាយមិនញាត់ម្រាមដៃទាំងអស់

(ឋិ.៤.៤៦៤.)

**ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខាករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញកាលឆាន់បាយ នឹងមិនញាត់ (ម្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់ ។

## [១៨៨] **នសកពឡព្យាហរណ សិក្ខាបទទី ៤៣**

សិក្ខាបទ ការមិនឆាន់បោះដុំបាយទៅក្នុងមាត់

(ឋិ.៤.៤៦៥.)

**ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ ។

## [១៨៩] នបិណ្ឌុក្ខេបកវគ្គ សិក្ខាបទទី ៤៤

សិក្ខាបទ ការមិនឆាន់បោះដុំបាយ (ទៅក្នុងមាត់)

(បិ.៤.៤៦៦.)

**ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់បោះដុំបាយ (ទៅក្នុងមាត់) ។

## [១៩០] នកពឡាវច្ឆេទក សិក្ខាបទទី ៤៥

សិក្ខាបទ ការមិនឆាន់កាត់ពំនូតបាយ

(បិ.៤.៤៦៦.)

**ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់កាត់ពំនូតបាយ ។

## [១៩១] នអវគណ្ឌការកវគ្គ សិក្ខាបទទី ៤៦

សិក្ខាបទ ការមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់

(បិ.៤.៤៦៧.)

**ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់ ។

## [១៩២] នហត្ថនិទ្ធូនកវគ្គ សិក្ខាបទទី ៤៧

សិក្ខាបទ ការមិនឆាន់រលាស់ដៃ

(បិ.៤.៤៦៧.)

**ន ហត្ថនិទ្ធូនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់រលាស់ដៃ ។

**[១៩៣] នសិត្ថាវការកធុញ្វន សិក្ខាបទទី ៤៨**

សិក្ខាបទ ការមិនឆាន់ធ្វើគ្រាប់បាយឱ្យជ្រុះរោយរាយ

(បិ.៤.៤៦៨.)

**ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់ ធ្វើគ្រាប់បាយឱ្យជ្រុះរោយរាយ ។

**[១៩៤] នជិវ្ហានិច្ឆារកធុញ្វន សិក្ខាបទទី ៤៩**

សិក្ខាបទ មិនឆាន់លៀនអណ្ដាត

(បិ.៤.៤៦៨.)

**ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់លៀនអណ្ដាត ។

**[១៩៥] នចបុចបុការកធុញ្វន សិក្ខាបទទី ៥០**

សិក្ខាបទ ការមិនធ្វើសំឡេងឱ្យឮផ្ចប់ៗ

(បិ.៤.៤៦៩.)

**ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់ធ្វើសំឡេងឱ្យឮផ្ចប់ៗ ។

**ចប់កពឡវគ្គ ទី ៥**

**[១៩៦] នសុរុសុរុការកធុញ្វន សិក្ខាបទទី ៥១**

សិក្ខាបទ មិនឆាន់ធ្វើសំឡេងឱ្យឮគ្រូកៗ

(បិ.៤.៤៧១.)

**ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់ឱ្យឮសំឡេងគ្រូក ៗ ។

## [១៩៧] នហត្ថនិល្លេហកភុញ្ជន សិក្ខាបទទី ៥២

សិក្ខាបទ មិនឆាន់លិទ្ធដៃ

(បិ.៤.៤៧១.)

**ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធដៃ ។

## [១៩៨] នបត្តនិល្លេហកភុញ្ជន សិក្ខាបទទី ៥៣

សិក្ខាបទ មិនឆាន់លិទ្ធបាត្រ

(បិ.៤.៤៧២.)

**ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបាត្រ ។

## [១៩៩] នឱដ្ឋនិល្លេហកភុញ្ជន សិក្ខាបទទី ៥៤

សិក្ខាបទ មិនឆាន់លិទ្ធបបូរមាត់

(បិ.៤.៤៧២.)

**ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

## [២០០] នសាមិសបដិគ្គហណ សិក្ខាបទទី ៥៥

សិក្ខាបទ ដៃប្រឡាក់អាមិស

(បិ.៤.៤៧៤.)

**ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញមានដៃប្រឡាក់ដោយអាមិសៈ នឹងមិនទទួលភាជនៈទឹកសម្រាប់ឆាន់ ។

## [២០១] នសសិត្ថកឆឌ្ឍន សិក្ខាបទទី ៥៦

សិក្ខាបទ មិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយ

(បិ.៤.៤៧៦.)

**ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនចាក់ទឹកលាងបាត្រទាំង គ្រាប់បាយទៅក្នុងចន្លោះផ្ទះ ។

## ចប់ធម្មទេសនាបដិសំយុត្ត ១៦

## [២០២] នឆត្តបាណិទេសន សិក្ខាបទទី ៥៧

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកមានឆត្រក្នុងដៃ

(បិ.៤.៤៧៨.)

**ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺមានឆត្រនៅក្នុងដៃ ។

## [២០៣] នទណ្ឌបាណិទេសន សិក្ខាបទទី ៥៨

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកមានដំបងក្នុងដៃ

(បិ.៤.៤៧៩.)

**ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ ដល់មនុស្សគ្មានជំងឺមានដំបងក្នុងដៃ ។

## [២០៤] **នសត្ថបាណិទេសន សិក្ខាបទទី ៥៩**

សិក្ខាបទ មិនសម្ដែងធមិដល់អ្នកមានគ្រឿងសាស្ត្រាក្នុងដៃ

(បិ.៤.៤៨០.)

**ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសម្ដែងធមិដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ ។

## [២០៥] **នអាវុធបាណិទេសន សិក្ខាបទទី ៦០**

សិក្ខាបទ មិនសម្ដែងធមិដល់អ្នកមានគ្រឿងអាវុធក្នុងដៃ

(បិ.៤.៤៨០.)

**ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសម្ដែងធមិដល់មនុស្សគ្មានជំងឺ មានគ្រឿងអាវុធក្នុងដៃ ។

## **ចប់បាទុកាវគ្គទី ៧**

## [២០៦] នបាទុការុឡ្ហទេសន សិក្ខាបទទី ៦១

សិក្ខាបទ មិនសម្ដែងធម៌ដល់អ្នកពាក់ទ្រនាប់ជើង

(បិ.៤.៤៨២.)

**ន បាទុការុឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺពាក់ទ្រនាប់ជើង ។

## [២០៧] នឧបាហនទេសន សិក្ខាបទទី ៦២

សិក្ខាបទ មិនសម្ដែងធម៌ដល់អ្នកពាក់ស្បែកជើង

(បិ.៤.៤៨២.)

**ន ឧបាហនារុឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខាករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺពាក់ស្បែកជើង ។

## [២០៨] នយានគតទេសន សិក្ខាបទទី ៦៣

សិក្ខាបទ មិនសម្ដែងធម៌ដល់អ្នកនៅលើយាន

(បិ.៤.៤៨៣.)

**ន យានគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺនៅលើយានទេ ។

## [២០៩] នសយគតទេសន សិក្ខាបទទី ៦៤

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកនៅលើដំណេក
(ឋិ.៤.៤៨៤.)

**ន សយនគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺនៅលើដំណេក ។

## [២១០] នបល្លត្ថិកទេសន សិក្ខាបទទី ៦៥

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកអង្គុយត្របោមក្បាលជង្គង់
(ឋិ.៤.៤៨៤.)

**ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយត្របោមក្បាលជង្គង់ ។

## [២១១] នវេឋិតសីសទេសន សិក្ខាបទទី ៦៦

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកជួតក្បាល
(ឋិ.៤.៤៨៥.)

**ន វេឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺជួតក្បាល ។

## [២១២] នឧគ្គុណ្ឋិតសីសទេសន សិក្ខាបទទី ៦៧

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកទទូរក្បាល

(បិ.៤.៤៨៦.)

**ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ទទូរក្បាល ។

## [២១៣] នឆមាយទេសេន សិក្ខាបទទី ៦៨

សិក្ខាបទ មិនសម្តែងធម៌ដល់អ្នកអង្គុយនៅលើអាសនៈ

(បិ.៤.៤៨៦.)

**ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនអង្គុយផ្ទាល់នឹងផែនដីហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយនៅលើអាសនៈ ។

## [២១៤] ននីចាសនទេសន សិក្ខាបទទី ៦៩

សិក្ខាបទ អង្គុយលើអាសនៈទាប ហើយសម្តែងធម៌ដល់អ្នកមានអាសនៈខ្ពស់

(បិ.៤.៤៩១.)

**ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនអង្គុយនៅលើអាសនៈទាបហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ។

## [២១៥] នបិតទេសន សិក្ខាបទទី ៧០

សិក្ខាបទ មិនឈរសម្ដែងធម៌ដល់អ្នកដែលអង្គុយ

(បិ.៤.៤៩១)

**ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឈរសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលអង្គុយ ។

## [២១៦] នបច្ឆតោទេសេន សិក្ខាបទទី ៧១

សិក្ខាបទ មិនដើរខាងក្រោយសម្ដែងធម៌ដល់អ្នកដើរខាងមុខ

(បិ.៤.៤៩២)

**ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនដើរខាងក្រោយ សម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរខាងមុខ ។

## [២១៧] នឧប្បថទេសេន សិក្ខាបទទី ៧២

សិក្ខាបទ មិនដើរក្រៅផ្លូវសម្ដែងធម៌ដល់អ្នកដើរតាមផ្លូវ

(បិ.៤.៤៩២.)

**ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនដើរក្រៅផ្លូវ សម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរតាមផ្លូវ ។

**ចប់ធម្មទេសនាបដិសំយុត្ត ១៦**

## [២១៨] នបិតករណា សិក្ខាបទទី ៧៣

សិក្ខាបទ មិនឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ

(បិ.៤.៤៩៣.)

**ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថាអញគ្មានជំងឺនឹងមិនឈរបន្ទោបង់ឧច្ចារៈឬបស្សាវៈ ។

## [២១៩] នហរិតករណា សិក្ខាបទទី ៧៤

សិក្ខាបទ មិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ លើស្មៅស្រស់

(បិ.៤.៤៩៤.)

**ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញគ្មានជំងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ឬស្តោះទឹកមាត់ លើស្មៅស្រស់ ឬឈើស្រស់ ។

## [២២០] នឧទកករណា សិក្ខាបទទី ៧៥

សិក្ខាបទ មិនបន្ទោបង់ឧច្ចារៈ បស្សាវៈ ស្តោះទឹកមាត់ដាក់លើទឹក

(បិ.៤.៤៩៦.)

**ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញគ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹក ។

**ចប់បកិណ្ណក ៣**

**ចប់បាទុកវគ្គទី ៧**

**ចប់សេខិយវត្តកណ្ឌ**

វត្តព្រះគន្ធកុដិ

# អធិករណសមថកណ្ឌ

**[២២១]**.សម្មុខាវិនយោ ទាតព្វោ សង្ឃត្រូវឱ្យសម្មុខាវិន័យ

**[២២២]**.សតិវិនយោ ទាតព្វោ សង្ឃត្រូវឱ្យសតិវិន័យ

**[២២៣]**.អមូឡ្ហវិនយោ ទាតព្វោ សង្ឃត្រូវឱ្យអមូឡ្ហវិន័យ

**[២២៤]**.បដិញ្ញាយ ការេតព្វំ សង្ឃត្រូវវិនិច្ឆ័យតាមពាក្យប្ដេជ្ញារបស់ភិក្ខុអ្នកឆ្លើយ

**[២២៥]**.យេភុយ្យសិកា សង្ឃត្រូវវិនិច្ឆ័យ តាមពាក្យខាងច្រើន ជាប្រមាណ

**[២២៦]**.តស្ស បាបិយសិកា សង្ឃត្រូវធ្វើទោសតាមកម្មរបស់ភិក្ខុដែលប្រព្រឹត្តលាមក

**[២២៧]**.តិណវត្ថារកោតិ សង្ឃត្រូវវិនិច្ឆ័យ ឱ្យពួកភិក្ខុដែលវិវាទទាស់ទែងគ្នា លុបលាងបំបាត់ ហើយអត់ឱនគ្នាទៅវិញទៅមក ដូចជាគ្របមូត្រលាមកដោយស្មៅ ។

## ចប់អធិករណសមថកណ្ឌ

## សូមអនុមោទនា
## គម្ពីរជាឧបករណ៍ ក្នុងការរៀបរៀងសៀវភៅនេះឡើង

ព្រះវិន័យបិដកភាគ ១

ព្រះវិន័យបិដកភាគ ២

ព្រះវិន័យបិដកភាគ ៣

ព្រះវិន័យបិដកភាគ ៤

អដ្ឋកថាសមន្តប្បាសាទិកាភាគ១

អដ្ឋកថាសមន្តប្បាសាទិកាភាគ២

អដ្ឋកថាសមន្តប្បាសាទិកាភាគ៣

បោះពុម្ពលើកទី ១ ចំនួន ២៤០ ក្បាល
២,២២០,000 រៀល
វត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង
ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍  ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹងថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣
ភិក្ខុមេត្តាធរោ មឿន សឺន

**ឈ្មោះសៀវភៅ** **សិក្ខាបទវិភង្គបាលីប្រែ ( ២២៧សិក្ខាបទ )**

**រៀបរៀងដោយ** **មេត្តាធនោ មឿន សឺន**

**ជួយពិនិត្យដោយ** **សន្តចិត្តោ រ៉េន រដ្ឋា**

**ជវនប្បញ្ញោ ឡុង ជីវ៉ា**

**អនុត្តរធម្មោ នី សុផានុត**

**អត្ថកាមោ មិន រដ្ឋា**

**សុខសេង មនោកញ្ញា**

**ប្អូនស្រី ប៉ោ ហៀលាត**

**កាលបរិច្ឆេទ** ថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៣

ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ (ច.ផ.)

ថ្ងៃ ១៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ (ប.ច.)

**ទីតាំងធ្វើ** **វត្តព្រះគន្ធកុដិ ( អាស្រមព្រះគន្ធកុដិ )**

ភូមិរំចេក៣ សង្កាត់ រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

## នាមពុទ្ធបរិស័ទដែលមានសទ្ធា
## បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

| ល.រ | នាមពុទ្ធបរិស័ទ | រៀល | ដុល្លារ | ចំនួនសៀវភៅ |
|---|---|---|---|---|
| ១ | ភិក្ខុសូរបណ្ឌតោ សេង សុនឿន | ១០ ម៉ឺន | | ១០ |
| ២ | ភិក្ខុមេត្តាបាលោ សឿប វណ្ណៈ | | ២៥ $ | ១០ |
| ៣ | ភិក្ខុវិរិយបាលោ មី នី | | ២០ $ | ៨ |
| ៤ | ភិក្ខុចាគរតោ ផាត់ សុភន | ១០ ម៉ឺន | | ១០ |
| ៥ | ឧ.សិ. តួវ នារីផល | | ២០ $ | ៨ |
| ៦ | ឧ.សិ. ជា សុណារី | | ២០ $ | ៨ |
| ៧ | ឧ.សិ. សុខសេង មនោកញ្ញនា និង ស្វាមី | | ១៥ $ | ៦ |
| ៨ | ឧបាសិកា ទូត ច័ន្ទវណ្ណី | | ៥០ $ | ២០ |
| ៩ | ឧ.សិ ម៉ិញ ស៊ីតារា ព្រមទាំងស្វាមីនិងបុត្រ | | ៥០ $ | ២០ |
| ១០ | ឧ.ស. សុខ គុណរិទ្ធ ឧ.សិ. ថាប់ មុំ | | ២០ $ | ៨ |
| ១១ | ឧ.សិ អ៊ឹង ដាលីដា ព្រមទាំងបុត្រ | | ២០ $ | ៨ |
| ១២ | ឧ.សិ សេង ចន្ធី ព្រមទាំង បុត្រ | | ១៣ $ | ៥ |
| ១៣ | ឧ.សិ. ម៉ឹង យឿន ព្រមទាំង កូនចៅ | ៥ ម៉ឺន | | ៥ |
| ១៤ | ឧ.សិ សិរីពៅ ព្រមទាំង កូនចៅ | ១០ ម៉ឺន | | ១០ |
| ១៥ | ឧ.ស. ខាត សារិទ្ធ ព្រមទាំងភរិយា | ៦ ម៉ឺន | | ៦ |
| ១៦ | ឧ.សិ.មុំ ពោធិវង្ស និងស្វាមីព្រមទាំងបុត្រ | ១០ ម៉ឺន | | ១០ |
| ១៧ | ឧ.សិ. ស៊ុំ សុខមួយ ព្រមទាំងបុត្រ | | ២០ $ | ៨ |
| ១៨ | ឧ.សិ. មូល ដាលី | ២ ម៉ឺន | | ២ |
| ១៩ | ឧ.សិ. ឃុត វ៉ាន់ថា និងកូនចៅ | ២ ម៉ឺន | | ២ |
| ២០ | ឧ.សិ.កង កញ្ញា ព្រមទាំងអ្នកម្តាយនិងកូនចៅ | ២ ម៉ឺន | | ២ |

## សៀវភៅដែលរៀបរៀងដោយ
## ភិក្ខុមេត្តាធនោ មឿន សឺន

១.ភិក្ខុបាតិមោក្ខបាលី

២.សង្ឃកម្មសង្ខេប

៣.ទេវទូតសូត្រ (ទេវទូត ៣ ពួក )

៤.ព្រះគាថាពន្ធ

៥.ពិធីបុណ្យបូជាព្រះសពលោកគ្រូធម្មបាលោ ប្រាក់ ឃុន

៦.ខគ្គវិសាណសុត្តន្ត ខគ្គវិសាណអដ្ឋកថា

៧.ខគ្គវិសាណសូត្រ ( ៤១ ព្រះគាថា )

៨.សិក្ខាបទវិភង្គបាលីប្រែ ( ២២៧ សិក្ខាបទ )

**សូមអនុមោទនា !!!**

**សូមអរគុណ**

**ឧបាសក ស្រ៊ុង ចាន់ណា (Srong Channa )**

**ម្ចាស់គេហទំព័រ ៥០០០ ឆ្នាំ**

**ដែលតែងតែបានជួយផ្សាយធម្មទានផ្សេងៗ**




## ថេរគាថា ព្រះឧបាលិត្ថេរៈ

សទ្ធាយ  អភិនិក្ខម្ម    នវបព្វជិតោ នវោ
មិត្តេ ភជេយ្យ កល្យាណេ    សុទ្ធាជីវេ អតន្ទិតេ ។

កុលបុត្ត ចេញ (ចាកឃរាវាស) ដោយសទ្ធា ហើយបួសថ្មី ជានវភិក្ខុ គប្បីគប់រកកល្យាណមិត្រទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។

សទ្ធាយ  អភិនិក្ខម្ម    នវបព្វជិតោ នវោ
សង្ឃស្មឹ វិហរំ ភិក្ខុ    សិក្ខេថ វិនយំ ពុធោ ។

កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធា  ហើយបួសថ្មី  ជានវភិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួក គប្បីសិក្សានូវវិន័យ ។

សទ្ធាយ  អភិនិក្ខម្ម    នវបព្វជិតោ នវោ
កប្បាកប្បេសុ កុសលោ    ចរេយ្យ អបុរក្ខតោ ។

កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធា  ហើយបួសថ្មី  ជានវភិក្ខុ ជាអ្នកឈ្លាស  ក្នុងហេតុដែលគួរនិងមិនគួរទាំងឡាយ  គប្បីប្រព្រឹត្តកុំឱ្យ (ពួកកិលេសមានតណ្ហាជាដើម) ប្រព្រឹត្តទៅក្នុងខាងមុខបាន ។

(សុត្តន្តបិដក ៥៦/ ទំព័រ ២០១)